ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអប់រំ យុវជន និងកីឡា

# គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យគុណភាព នៃការសាងសង់អគារសិក្សា

*ខែកក្កដា ឆ្នាំ ២០១២*

## អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកការអភិវឌ្ឍន៍វិស័យអប់រំ ជាចំណុចស្នូលនៃការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចសង្គម ជាមួយគ្នានេះដែរការអភិវឌ្ឍន៍ធនធានមនុស្សស្ថិតក្នុងមុំទី១ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ដើម្បីសម្រេចឲ្យបាននូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបាន ប្តេជ្ញាចិត្តយ៉ាងខ្ពស់ក្នុងការពន្លឿនការរីកចម្រើនឆ្ពោះទៅសម្រេចបានគុណភាពអប់រំ និងសម្រេច គោលដៅអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ២០១៥តាមរយៈការធានាឲ្យបានសមធម៌នៃការចូល រៀន ការធ្វើឲ្យប្រសើរឡើងគុណភាពអប់រំ ប្រសិទ្ធភាពនៃសេវាកម្មអប់រំ ការអភិវឌ្ឍន៍ស្ថាប័ន និង សមត្ថភាពមន្ត្រីរាជការសម្រាប់សហវិមជ្ឈការ ។

នៅក្នុងទសវត្សចុងក្រោយនេះ ក្រសួងអប់រំ យុវជននិងកីឡាបានសម្រេចស្នាដៃគួរឲ្យកត់សំគាល់ ក្នុងការធ្វើឲ្យប្រសើរឡើងការអប់រំមូលដ្ឋានរបស់កុមារទាំងពីរភេទ ។ អត្រាពិតនៃការសិក្សានៅ បឋមសិក្សាបានកើនឡើងដល់៩៦% កំណើននេះធ្វើឲ្យអត្រារួមនៃការសិក្សានៅមធ្យមសិក្សា

បឋមភូមិកើនឡើងទ្វេដងដល់៥៨%។ទោះបីសម្រេចបានស្នាដៃជាច្រើនបែបនេះក្តី ក៏វិស័យអប់រំ នៅជួបការប្រឈមជាច្រើនទៀតក្នុងការសម្រេចបានទាំងគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ទាំងគោលដៅអភិវឌ្ឍន៍សហសវត្សនៃការអប់រំ៩ឆ្នាំនៅបឋមសិក្សា ព្រោះថា សិស្សានុសិស្សជា ច្រើនមិនបានបន្តការសិក្សារបស់គេនៅមធ្យមសិក្សា ដោយសារសាលារៀននៅឆ្ងាយ និងសាលា រៀននៅទីក្រុងមានសិស្សច្រើនលើសកំណត់ ។ ឧទាហរណ៍ជាក់ស្តែងមាន១៨៧ឃុំ ក្នុងចំណោម ឃុំសរុបចំនួន១៦២១ មិនទាន់មានសាលាមធ្យមសិក្សានៅឡើយ និងនៅតាមទីប្រជុំជនខ្លះការ បង្រៀនប្រព្រឹត្តទៅពីរវេន និងមិនអាចស្រូបយកសិស្សថែមទៀតបាន។ ដោយហេតុនេះ ការជួស ជុលអគារសិក្សាចាស់ៗ និងសាងសង់ថ្មីពិតជាចាំបាច់ពិតប្រាកដ ។

ក្រសួងអប់រំ យុវជន និងកីឡាបានកសាងគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យគុណភាព សំណង់សាលារៀននេះ ក្នុងគោលបំណងជួយ និងចង្អុលបង្ហាញនាយកដ្ឋានសំណង់ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រាជធានី សាលារៀន វិស្វករ នាយកសាលា គណៈកម្មាការទ្រទ្រង់សាលា អ្នកម៉ៅការ ក្នុងការគូសប្លង់ ធ្វើផែនការ អនុវត្តការងារ និងតាមដានការសាងសង់សាលារៀននៅ

ក្នុងប្រទេសកម្ពុជា និងធ្វើយ៉ាងណាឲ្យសាលារៀនមានសុវត្ថិភាព មានបរិស្ថានល្អសម្រាប់រៀន និងបង្រៀន ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះមន្ត្រីអប់រំទាំងអស់ដែលមានការពាក់ព័ន្ធ អ្នកពិគ្រោះការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ ជាពិសេសធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់នាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំ និងអភិវឌ្ឍន៍គោលការណ៍ណែនាំនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០១២

**អ៊ឹម សិទ្ធី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**មាតិកា** **ទំព័រ**

I- បុព្វកថា ៩

II- ការងារបរិស្ថាន ពលកម្ម សុវត្ថិភាព ១០

២-១. ការ ការពារបរិស្ថាន ១០

២-២. ការងារពលកម្ម ១០

២-៣. ការ ការពារប្រភពទឹក ១០

២-៤. ការគ្រប់គ្រង ASBESTOS ១១

២-៥. សំឡេង និងភាពកខ្វក់ជា ធូលី ១១

២-៦. ការរំខាន ១១

២-៧. មីន និងគ្រឿងផ្ទុះផ្សេងៗ (UXO) ១២

២-៨. ការ ការពារធនធានប្រវត្តិសាស្ត្រ និងវប្បធម៌ជាតិ ១២

២-៩. ទឹកស្អាត និងរចនាសម្ព័ន្ធអនាម័យ ១២

២-១០. ការពិនិត្យតាមដាន គ្រប់គ្រង និងធ្វើរបាយការណ៍ ១២

III.លំអិតបច្ចេកទេសនៃការសាងសង់និងតម្រូវការចាំបាច់នៃការបំពេញការងារ១៤

ក-ការងារសាងសង់ ១៤

១. ការងាររៀបចំការដ្ឋាន ១៤

១-១ ការងារសំអាតការដ្ឋាន ១៤

១-២ ការចាប់ផ្ដើមការដ្ឋាន ១៤

**២-ការងារគ្រឹះ** ១៥

២-១-ពិពណ៌នាអំពីបេតុងជើងតាង ១៥

២-២-ការជីកដី និង ការរៀបចំទ្រនាប់គ្រឹះ ១៥

២-៣-បេតុងជើងតាង ១៥

២-៤-ក្តារពុម្ពដើម្បីចាក់ជើងតាង ១៥

**៣-ជញ្ជាំងទប់ដី** ១៦

៤-ការចាក់ដីបំពេញ (ពិនិត្យលក្ខខ័ណ្ឌបង្ហាប់នៅក្នុងប្លង់លំអិត) ១៦
៥-ស្រទាប់គ្រឹះក្រោមកម្រាលបេតុង(សម្រាប់អគារខឿន១,៥០ម
និងតិចជាង) ១៦
៦-ធ្នឹមកម្រាល (សម្រាប់ខឿន ១,៥០ម និង តិចជាង) ១៦
៧-ធ្នឹមកម្រាល (សម្រាប់ខឿន ២,៥០ម និង ធំជាង) ១៧
៨-ធ្នឹមទ្រប្លង់សេ (សម្រាប់ខឿន ២,៥០ម និង ធំជាង) ១៧
៩-ធ្នឹមទ្រប្លង់សេ (សម្រាប់ខឿន ២,៥០ម និង ធំជាង) ១៧
១០-បេតុងអារមេប្លង់សេកម្រាល (សម្រាប់ខឿន ១,៥០ម និង តិចជាង) ១៧
១១-បេតុងអារមេប្លង់សេកម្រាល (សម្រាប់ខឿន ២,៥០ម និង ធំជាង) ១៨
១២-សសរបេតុងអារម៉េ ១៨
១៣-ធ្នឹមលើ ១៨
១៣,១-ធ្នឹមមេទទឹងបន្ទប់ (ទំហំ ២៥ស.ម x ៤០ស.ម) ១៩
១៣,២-ធ្នឹមក្រវ៉ាត់កាត់ទទឹងបន្ទប់លើជញ្ជាំងខ័ណ្ឌ
(ទំហំ២០ស.ម x ២០ស.ម) ១៩
១៣,៣-ធ្នឹមក្រវ៉ាត់ទិសដៅបណ្តោយ ១៩
១៤-ធ្នឹមបេតុងអាម៉េទ្រដំបូល (ទំហំ ១៥ស.មx២៥ស.ម) ១៩
១៥-ឡាំងតូលើទ្វារ បង្អួច និងឡាំងតូក្រោមបង្អួច
(ទំហំ ១០ស.មx២០ស.ម) ១៩
១៦-ឡាំងតូក្រោមបង្អួច (ទំហំ ១០ស.មx២០ស.ម) ២០
១៧-បាំងសាចលើបង្អួច ២០
១៨-បេតុងកម្រាលជុំវិញអគារ ២០
១៩-គុណភាពនៃការងារបេតុង និង ការថែទាំបេតុង ២០
២០-ជញ្ជាំងឥដ្ឋនៅចន្លោះសសរ ២០
២១-ឥដ្ឋ ២១
២២-ប្លុកឥដ្ឋខ្យល់ ២១

២៣-ការងារបូកសម្អាតសសរ និង ធ្នឹម ២១
២៤-ការងារបូកសម្អាតជញ្ជាំង ២២
២៥-ការតំឡើងគ្រឿងដំបូលដែក ២២
២៦-គុណភាពក្បឿង ២២
២៧-ទ្វារ(ឈើ) ២៣
២៨-បង្អួច(ឈើ) ២៣
២៩-គ្រឿងបង្កុំទ្វារ និង គ្រឿងបង្កុំបង្អួច ២៣
៣០-គ្រោងទ្វារ និង គ្រោងបង្អួច(ឈើ) ២៣
៣១-ត្រចៀកបង្អួច និងត្រចៀកទ្វារ ២៤
៣២-រនុកទ្វារ និង រនុកបង្អួច ២៤
៣៣-ការតម្លើងគ្រឿងទ្វារ និង បង្អួច ២៤
៣៤-ការលាបថ្នាំទ្វារ និងបង្អួច ២៤
៣៥-ការលាបថ្នាំចំរឹងបង្អួច ២៥
៣៦-ការលាបកំបោរ ២៥
៣៧-បង្គន់អនាម័យ ២៥
**ខ-សេចក្តីណែនាំលំអិតលក្ខណៈបច្ចេកទេសនៃសម្ភារៈ ២៥**
១-ល្បាយបេតុង ២៥
២-វិធីលាយបេតុង ២៥
៣-ស៊ីម៉ង់ត៍ ២៦
៤-ខ្សាច់ ២៦
៥-ថ្ម ២៦
៦-ដែកសសៃ ២៦
៧-ទឹក ២៧
៨-ការចាប់បេតុង ២៧
៩-ការប្រើម៉ាស៊ីនរំញ័រក្នុងការងារចាក់បេតុង(Vibrator) ២៧

១០-ការថែរក្សាបេតុង ២៧
១១-គោលការណ៍នៃការលាយបេតុង ២៨
១២-បាយអរ ២៨
**គ-ការអនុម័ត ឬ ឯកភាពលើការប្រើប្រាស់សម្ភារៈ ២៨**
**ឃ-អណ្តូងទឹក ២៩**
១-ទីតាំងដែលត្រូវខួង ២៩
២-គំនូសប្លង់ ២៩
៣-អង្កត់ផ្ចិតអណ្តូង ២៩
៤-ធាទឹក និងជម្រៅ ២៩
៥-ស្នប់អណ្តូង ២៩
៦-ការខួងអណ្តូងឡើងវិញ ៣០
៧-ជម្រៅរបស់បំពង់ចម្រោះ (Filter) ៣០
៨-បំពង់ជ័រ និងបំពង់ចម្រោះ (Filter) ៣០
៩- ឯកសារ Log Sheet ៣០
១០- ជើងទ្រស្នប់ ៣០
១១- ការឆ្លងប៉ាក់តេរីចូលអណ្តូងពេលកំពុងសាងសង់ ៣១
១២- ខឿនអណ្តូង ៣១
១៣- ការចេញចូលការដ្ឋាន ៣១
១៤- ការទុកដាក់សម្ភារសំណង់ ៣១
១៥- មិនមានការទូទាត់ប្រាក់សំរាប់អណ្តូងស្ងួត ៣១
១៦- ការធ្វើពិសោធន៍លក្ខណៈរូប និងលក្ខណៈគីមី ៣១
១៧- ការសម្លាប់មេរោគសំរាប់អណ្តូង ៣២
១៨- ការលុបចេញការងារពីកម្មវិធីការងារ ៣២
១៩- ការបញ្ចប់ការសាងសង់ ៣២
២០- ការថែទាំ និងរយៈពេលសុពលភាព ៣៣

## IV ការគ្រប់គ្រងការដ្ឋាន និងការពិនិត្យតាមដាន ៣៣


៤-១ នាយកដ្ឋានសំណង់ ៣៣

៤-២ ការងារត្រួតពិនិត្យតាមដានរបស់វិស្វករក្រសួងអប់រំ យុវជន និងកីឡា ៣៤

៤-៣ ការទទួលខុសត្រូវរបស់វិស្វករប្រចាំការដ្ឋាន ៣៨

៤-៤ ការចូលរួមរបស់នាយកសាលា និងគណៈកម្មការទ្រទ្រង់សាលា ៣៦

៤-៥ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៣៧

៤-៦ ក្រុមហ៊ុនសាងសង់ ៣៩

## បុព្វកថា

ឯកសារគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យគុណភាពសំណង់អគារសិក្សាថ្មី មានខ្លឹមសារ និងគោលការណ៍រួមដើម្បីរក្សានូវសុវត្ថិភាព និងធានាបាននូវគុណភាពសំណង់អគារសិក្សានៅក្នុងប្រទេសកម្ពុជា ។ គោលការណ៍ណែនាំនេះបានរំលេចនូវការការពារសុវត្ថិភាព វិធានការការពារបរិស្ថានចាំបាច់ព្រមទាំងបានរំលេចនូវលំអិតបច្ចេកទេស និងតម្រូវការចាំបាច់ក្នុងគ្រប់ជំហាននៃការសាងសង់អគារសិក្សាថ្មី ព្រមទាំងមានយន្តការក្នុងការត្រួតពិនិត្យ និងវាយតម្លៃទៀតផង។

គោលការណ៍ណែនាំនេះ បង្កើតឡើង សម្រាប់ផ្តល់ជូនមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានជំនាញដែលពាក់ព័ន្ធនឹងការងារនេះប្រើប្រាស់ ។ ក្នុងនោះមាននាយកដ្ឋានសំណង់ នៃក្រសួង អប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រាជធានី សាលារៀន ក្រុមហ៊ុនសំណង់ គណៈកម្មការទ្រទ្រង់សាលារៀន និងដៃគូអភិវឌ្ឍនិដទៃទៀត។

គោលការណ៍ណែនាំនេះ នឹងប្រើប្រាស់ដំណាលគ្នាជាមួយឯកសារប្លង់លំអិត របស់នាយកដ្ឋានសំណង់ នៃក្រសួងអប់រំយុវជននិងកីឡា ល័ក្ខខ័ណ្ឌទូទៅនៃកិច្ចសន្យា លក្ខខ័ណ្ឌពិសេសនៃកិច្ចសន្យា គោលការណ៍ និងនិតិវិធីលទ្ធកម្ម ។

វត្ថុបំណងចំបងនៃការបង្កើតគោលការណ៍ណែនាំនេះ គឺដើម្បីធានាថា ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានជំនាញ ក្រុមហ៊ុនសាងសង់ មានការទទួលខុសត្រូវលើការបំពេញការងាររបស់ខ្លួននិងដើម្បីធានាថាការសាងសង់អគារសិក្សានៅព្រះរាជាណាចក្រកម្ពុជាទទួលបាននូវគុណភាពទាន់ពេលវេលា មានប្រសិទ្ធិភាពនិងតាមផែនការថវិកា ហើយនិង ស្របតាមស្តង់ដាបច្ចេកទេសដែលបានឯកភាព។

សេចក្តីណែនាំមានលក្ខណៈរស់រវើក ដែលនឹងអាចធ្វើការអភិវឌ្ឍនិ និងកែលំអស្របតាមក្នុងពេលវេលា នៅពេលទទួបានបទពិសោធន៍និងមេរៀនតាមរយៈការអនុវត្ត ការងារគម្រោងសាងសង់សាលារៀនជាបន្តបន្ទាប់ ។

ដោយហេតុនេះអ្នកប្រើប្រាស់គោលការណ៍ណែនាំនេះ ត្រូវបានលើកទឹកចិត្ត ឲ្យជួយស្វែងរកចំណុចខ្វះខាត និងលើកឡើងនូវសំណើ កែលំអដែលចាំបាច់នៅក្នុងដំណើរការនេះ។

## II.ការការពារបរិស្ថាន ការងារ និង សុវត្ថិភាព

### ២-១. ការ ការពារបរិស្ថាន

ក្រុមហ៊ុនទទួលបន្ទុកសាងសង់ចាំបាច់ត្រូវធ្វើយ៉ាងណាឲ្យការខូចខាតដល់បរិស្ថានដែលបណ្តាលមកពីការងារសាងសង់នេះមានកម្រិតអប្បរមា ។ ក្នុងករណីដែលការខូចខាតកើតមានឡើងចំពោះបរិស្ថាន ដូចជាដើមឈើ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងការដ្ឋានដោយក្រុមហ៊ុននោះ ក្រុមហ៊ុនធានាថា ការខូចខាតទាំងនោះត្រូវបានជួសជុល ឬកែលំអ រក្សាឲ្យបាននូវសភាពដើមវិញ ឬសងការរការខូចខាតទាំងនោះ ។

### ២-២. បទដ្ឋានការងារ

ក្រុមហ៊ុនទទួលបន្ទុកសាងសង់ ចាំបាច់ត្រូវគោរពនូវច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាការងារអន្តរជាតិនានាដូចជា មិនត្រូវប្រើប្រាស់កម្លាំងពលកម្មកុមារមិនគ្រប់អាយុ ឬកុមារមានអាយុតិចជាង១៨ឆ្នាំនៅក្នុងការងារប្រកបដោយគ្រោះថ្នាក់ មិនត្រូវបង្ខិតបង្ខំកម្មករ និងមិនត្រូវរើសអើង ក្នុងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ឈ្នួលការងារ និងប្រាក់ឧបត្ថម្ភនានា ។ ក្រៅពីនេះក្រុមហ៊ុនសាងសង់ត្រូវ រកវិធីសាស្ត្រកាត់បន្ថយភាពដែលងាយគ្រោះថ្នាក់ ហើយនិងចាត់វិធានការកាត់បន្ថយឲ្យនៅតិចបំផុត តាមររយៈការបណ្តុះបណ្តាលកម្មករឲ្យបានត្រឹមត្រូវមុននឹងឲ្យចូលបំពេញការងារក្នុងការដ្ឋានសាងសង់។

### ២-៣. ការ ការពារប្រភពទឹក

ចំពោះប្រភពទឹកដែលមានក្នុងទីតាំងសាងសង់ ដូចជាអណ្តូងទឹក ស្រះ ប្រឡាយ អូរ ស្ទឹង ។ល។ ក្រុមហ៊ុនសាងសង់មិនត្រូវចោលសំរាម កាកសំណល់ការដ្ឋាន ឬទឹកសំអុយពីការដ្ឋាន ដូចជាលាងសំអាតមានសារធាតុគីមីផ្សេងៗ និង ហាមបង្ហូរចូលទីតាំងនៃប្រភពទឹកដូចបានរៀបរាប់ខាងលើ ។

## ២-៤. ការគ្រប់គ្រង ( ASBESTOS )

ក្រុមហ៊ុនសាងសង់ត្រូវទទួលខុសត្រូវលើសម្ភារ:សំណង់ដែលមិនអនុញ្ញាតឲ្យមានសម្ភារ:ទាំងឡាយណាដែលពាក់ព័ន្ធនឹងសារធាតុAsbestosក្នុងការងារសាងសង់អគារសិក្សាឡើយ ។ ចំពោះប្រការជាក់ស្តែងបើនៅការដ្ឋានមានសំណល់អគារចាស់ដែលត្រូវវាយចោល និងយកកាកសំណល់ចេញពីការដ្ឋានដែលមានសារធាតុ Asbestos។ ក្រុមហ៊ុនសាងសង់ត្រូវទទួលបន្ទុករុះរើ និងសំអាតចេញពីការដ្ឋាន ហើយការសំអាតចេញនេះត្រូវធ្វើឲ្យបានម៉ត់ចត់ និងប្រុងប្រយ័ត្ន និងពិភាក្សាជាមួយអ្នកបច្ចេកទេសឲ្យបានត្រឹមត្រូវ ។ ការរុះរើប្រភេទ Asbestos ត្រូវស្ថិតនៅក្នុងសភាពជាសំណើម ដើម្បីការពារនូវភាពហុយ ។ ចំពោះកាកសំណល់ដែលបានពីការរុះរើនេះត្រូវកំណត់ ទីតាំងចោលកាកសំណល់ទាំងនេះ ដោយមានការឯកភាពជាផ្លូវច្បាប់ពីអាជ្ញាធរមូលដ្ឋានត្រូវចោលកាកសំណល់នេះ។ ចំពោះវិធីសាស្ត្រសម្រាប់រុះរើរបស់ក្រុមហ៊ុនលើប្រភេទសម្ភារ:នេះត្រូវធានាឲ្យបាននូវលក្ខណ:ច្ចេកទេសត្រឹមត្រូវដែលមិនមានផលប៉ះពាល់លើការងារបរិស្ថាន និងសុខភាពកម្មករ និងអ្នកស្នាក់អាស្រ័យក្បែរនោះ ។

## ២-៥. សំឡេង និងភាពកខ្វក់ជា ធូលី

ក្រុមហ៊ុនសាងសង់ត្រូវធានាថាមិនបង្កនូវសំឡេងថ្លង់ ឬធូលីហ៊ុយដែលប៉ះពាល់ដល់បរិស្ថាន និងការរស់នៅរបស់ប្រជាជនជុំវិញបរិវេណសាងសង់ ។ រាល់សម្ភារ: និងឧបករណ៍ម៉ាស៊ីនប្រើប្រាស់ក្នុងដំណើរការដ្ឋានសាងសង់ត្រូវរៀបចំឲ្យមានសណ្តាប់ធ្នាប់និងទុកដាក់ក្នុងកន្លែងត្រឹមត្រូវតាមលក្ខណ:បច្ចេកទេសជាពិសេសមិនបង្កនូវសំលេងថ្លង់ ។ ចំពោះសកម្មភាពវាយចោលដូចជាប្រើប្រាស់វិធីសាស្ត្រផ្សេងៗនាំឲ្យមានធូលី និងផ្សែងត្រូវតែរកវិធីជំនួសពីលក្ខខ័ណ្ឌទាំងនេះ និងដោយបាញ់ទឹកជាសំណើម ដើម្បីកាត់បន្ថយបញ្ហាធូលីនេះជាដើម ។ ការងារទាំងនេះចាំបាច់មានការឯកភាពពីអ្នកបច្ចេកទេស។

## ២-៦. ការរំខាន

រយ:ពេលសាងសង់វែង និងការងារសាងសង់អាចរំខានដល់ការិយាល័យ បុគ្គលិក និងប្រជាជន ដែលនៅក្បែរការដ្ឋានសាងសង់ ។ អាស្រ័យហេតុនេះក្រុមហ៊ុនសាងសង់ចាំបាច់ត្រូវលៃលកពេលវេលាបំពេញការងារឲ្យបានសមស្របនិងមិនរំខានដល់ការបំពេញការងារ និងការរស់នៅរបស់ប្រជាជនក្បែរការដ្ឋានសាងសង់នោះ។

## ២-៧. មីន និងគ្រឿងផ្ទុះផ្សេងៗ (UXO)

ចំពោះមីន និងគ្រឿងផ្ទុះផ្សេងៗ ត្រូវទទួលខុសត្រូវដោយម្ចាស់សំណង់ (ក្រសួងអប់រំ យុវជន និងកីឡា) ក្នុងការងារសំអាតចេញពីការដ្ឋាន ។ ក្នុងនេះម្ចាស់សំណង់ត្រូវទាក់ទង នឹងសមត្ថកិច្ចទទួលបន្ទុកការងារបោសសំអាតមីន និងគ្រឿងផ្ទុះផ្សេងៗ ។ ក្រុមហ៊ុនសាងសង់ត្រូវរង់ចាំនូវការបញ្ជាក់ច្បាស់លាស់ថា ទីតាំងសាងសង់ត្រូវបានសំអាត ឬក៏ធានាថាគ្មានគ្រឿងផ្ទុះទេ ទើបអាចចាប់ផ្តើមការងារសាងសង់បាន ។ បើសិននៅក្នុងដំណើរការសាងសង់ជួបនូវបញ្ហាដែលពាក់ព័ន្ធនឹងគ្រឿងផ្ទុះ ក្រុមហ៊ុនត្រូវបញ្ឈប់ការងារជាបន្ទាន់ និងផ្តល់ពត៌មានដល់ម្ចាស់សំណង់ដើម្បីទាក់ទងសមត្ថកិច្ចចុះសំអាតរួចរាល់ ទើបអាចបន្តការងារសាងសង់បាន ។ ក្រុមហ៊ុនសាងសង់ពុំមានសិទ្ធក្នុងការទាមទារប្រាក់បន្ថែមផ្សេងៗ ក្នុងករណីបញ្ឈប់ការងារសាងសង់ដោយជួបបញ្ហានេះទេ ។

## ២-៨. ការ ការពារសម្បត្តប្រវត្តសាស្រ្ត និងវប្បធម៌

ក្រុមហ៊ុនសាងសង់ត្រូវទទួលខុសត្រូវលើកការការពារនូវសម្បត្តិប្រវត្តិសាស្រ្ត និងសម្បត្តិវប្បធម៌ដោយធ្វើរនាំង ឬរបងខ័ណ្ឌការពារលើការប៉ះពាល់ផ្សេងៗលើសម្បត្តិទាំងអស់នេះ។ចំពោះម្ចាស់សំណង់មិនអាចឯកភាពឲ្យធ្វើការសាងសង់សំណង់ថ្មីប៉ះពាល់ដល់សម្បត្តិប្រវត្តិសាស្រ្ត និងវប្បធម៌។ចំពោះក្រុមហ៊ុនសាងសង់ត្រូវរក្សាការពារឲ្យបាននូវពេលជួបប្រទះនូវវត្ថុបុរាណ វប្បធម៌ទោះជាមានចលនា ឬ គ្មានចលនា ផ្នូរបុរាណ ។ល។ ការងារសាងសង់ត្រូវផ្អាកជាបណ្តោះអាសន្នហើយអាចបន្តបាននូវពេលរកដំណោះស្រាយរួចរាល់ជាស្ថាពរ ។ ចំពោះការផ្អាក ទាំងឡាយនេះម្ចាស់សំណង់មិនទទួលខុសត្រូវលើការទូទាត់ជូនក្រុមហ៊ុនសាងសង់ឡើយ ។

## ២-៩. ទឹកស្អាត និងរចនាសម្ព័ន្ធអនាម័យ

ក្រុមហ៊ុនសាងសង់ត្រូវទទួលបន្ទុកដោះស្រាយឲ្យបាននូវបញ្ហាទឹកស្អាតនិងបង្គន់អនាម័យជាបណ្តោះអាសន្នក្នុងករណីទីតាំងសាងសង់រចនាសម្ព័ន្ធពុំមាន ។

ដំណោះស្រាយលើរចនាសម្ព័ន្ធអនាម័យទាំងនេះត្រូវធ្វើឡើងមានភាពសាមញ្ញងាយរុះរើនិងងាយគ្រប់គ្រងនៅក្នុងការដ្ឋាន ។ ចំពោះរចនាសម្ព័ន្ធអនាម័យទាំងអស់នេះ ត្រូវមានចំងាយយ៉ាងហោចណាស់ចាប់ពី ៣០ម ពីប្រភពទឹកស្អាត ឬ៣០ម ពី គែមមាត់ស្ទឹង បឹង ស្រះ ។ល។ ដែលមាន

នៅក្បែរការដ្ឋានសាងសង់នោះ ។ ជាការចាំបាច់ទីតាំងរចនាសម្ព័ន្ធអនាម័យត្រូវមានការឯកភាពពីអ្នកជំនាញបច្ចេកទេសដែលម្ចាស់សំណង់បានចាត់តាំងឲ្យទទួលខុសត្រូវ ។

## ២-១០. ការពិនិត្យតាមដាន ការគ្រប់គ្រង និងការធ្វើរបាយការណ៍

ក្រុមហ៊ុនសាងសង់ ដែល ទទួលបានការជ្រើសរើសឲ្យសាងសង់ចាំបាច់ដាក់ផែនការជាក់លាក់របស់ខ្លួនមកនាយកដ្ឋានសំណង់មុននឹងចាប់ដំណើរការងារសាងសង់។ ផែនការលម្អិតរបស់អ្នកម៉ៅការ ត្រូវមានបញ្ចូលផែនការគ្រប់គ្រងបរិស្ថានឲ្យបានច្បាស់លាស់ដូចខាងក្រោមៈ

(ក) បញ្ហាបរិស្ថានដែលអាចកើតមានឡើងក្នុងពេលសាងសង់

(ខ) ដំណោះស្រាយ ឬតើអ្នកម៉ៅការត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយបញ្ហាទាំងនោះ។

ក្រុមហ៊ុនសាងសង់ ដែល ទទួលបានការជ្រើសរើសឲ្យសាងសង់ចាំបាច់ត្រូវដាក់ផែនការជាក់លាក់របស់ខ្លួន ភ្ជាប់ក្នុងការស្នើសុំបើកប្រាក់របស់ខ្លួន ។ វិស្វករក្រសួង និងវិស្វករការដ្ឋាន នឹងធ្វើការពិនិត្យឡើងវិញដោយឡែកៗពីគ្នា ដោយប្រកាន់ខ្ជាប់នូវ ឯកសារបរិស្ថានក្នុងគ្រប់ការចុះត្រួតពិនិត្យតាមការដ្ឋាននីមួយៗ ។ គំរូនៃផែនការបរិស្ថានសម្រាប់ការសាងសង់សាលារៀនមាននៅក្នុងឧបសម្ព័ន។

## III. លក្ខណៈលំអិតបច្ចេកទេសសាងសង់ និងលក្ខខ័ណ្ឌតាមការចាំបាច់នៃបច្ចេកទេស

### ក-ការងារសាងសង់

### ១. ការងាររៀបចំការដ្ឋាន

### ១-១ ការងារសំអាតការដ្ឋាន

រុក្ខជាតិដែលប៉ះពាល់ទាំងអស់ត្រូវជំរះចេញឲ្យអស់ពីការដ្ឋាន ។ ការងារនេះត្រូវអនុវត្តដោយប្រុងប្រយ័ត្នជាទីបំផុត ។ សម្ភារៈទាំងឡាយណាដែលមានតម្លៃ ឬអាចប្រើប្រាស់ជាប្រយោជន៍ក្រោយពីការរុះរើ ត្រូវទុកជាទ្រព្យសម្បត្តិរបស់ភាគីម្ចាស់សំណង់។ ភាគីទទួលការងារសាងសង់ត្រូវដាក់សម្ភារៈរបស់ខ្លួនដាច់ដោយឡែកពីទ្រព្យសម្បត្តិរបស់ភាគីម្ចាស់សំណង់ ។ ភាគីទទួលការងារសាងសង់ចាំបាច់ត្រូវរៀបចំរបងសុវត្ថិភាព ធានាឲ្យបាននូវការងាររបស់ខ្លួនដោយមិនរំខានដល់ការបំពេញការងាររបស់បុគ្គលិកដែលមានទីតាំងនៅក្បែរឬក្នុងបរិវេណសាងសង់។របងសុវត្ថិភាពត្រូវរៀបចំធ្វើឡើងពីស័ង្កសីមានកំពស់1,7មៃត្រនិងបន្តពីកំពស់នេះចាំបាច់ត្រូវប្រើប្រាស់សំណាញ់ផ្លាស្ទីកបន្ថែម កំពស់២ម៉ែត្រ ។

### ១-២. ការចាប់ផ្តើមការដ្ឋាន

ភាគីទទួលការងារមៅការត្រូវបោះទីតាំងការដ្ឋាន ហើយធ្វើការកត់សម្គាល់ឲ្យបានច្បាស់ លាស់ដោយបោះបង្គោលចំណាំនៅគ្រប់កាច់ជ្រុងនៃទីតាំងទាំងអស់។ត្រូវបោះបង្គោលថែមទៀតចម្ងាយ **១.៥ម** ពីបង្គោលក្នុងទាំងនោះ និង បន្ទាប់មកវាយបន្ទះក្តារហ៊ុមព័ទ្ធបង្គោល គ្រាស់សេទាំងនោះ ហើយទាញរកខ្សែអក្សំឲ្យបានត្រឹមត្រូវ។ បន្ទាប់ពីទាញខ្សែអក្សំបានត្រឹមត្រូវ ហើយត្រង់ទីតាំងដែលត្រូវជីកត្រូវបោះបង្គោលចំណាំ។ការងារបោះបង្គោលនេះធានាបាននៅពេលជីកដីគ្រឹះគឺមានទីតាំង អាចងាយស្រួលដល់ការងារវាស់វែងនិងស្ទង់អ័ក្សសារជាថ្មី។ចំពោះទីតាំងដាក់សម្ភារះ និងកន្លែងស្នាក់នៅរបស់ក្រុមហ៊ុនសាងសង់ ដោយធានាឲ្យបាននូវគុណភាពសម្ភារះសំណង់ និង សុវត្ថិភាព សន្តិសុខ ។ហាមយកបន្ទប់សិក្សាមកដាក់សម្ភារះ និង ការស្នាក់របស់កម្មករ។

## ២-ការងារគ្រឹះ

## ២-១-ពិពណ៌នាអំពីបេតុងជើងតាង

ជាទូទៅ គ្រឹះជាប្រភេទគ្រឹះរាក់ មានភ្ជាប់ជាមួយឯកសារប្លង់ ។ហើយបន្តភ្ជាប់រហូតដលនីវ៉ូ កម្រាល 0,00 ដោយសសរគ្រឹះ ។ សសរគ្រឹះមានមុខកាត់ 200 x 200 mm សម្រាប់នីវ៉ូ 0,5 1,0 2,5 និង 3,50ម និង មុខកាត់250 X 250 mm សម្រាប់ ខឿន នីវ៉ូ 4,5m ។សសរគ្រឹះទាំងនេះ ទ្រដោយគ្រឹះបេតុងអារមេ ទំហំ 1000x1000x200 mm សម្រាប់អគារមានខឿនផ្ទាល់ដី និង 1400 x1400x 250mm សម្រាប់អគារមានខឿនផុតពីដី។ សំគាល់: សសរគ្រឹះ ទំហំ 200x200mm សម្រាប់អគារមានខឿន ( 0,5 1,0 2,5 3,50m) និងសសរគ្រឹះទំហំ 250x250mm សម្រាប់អគារ ខឿន 4,50m ។ មុខកាត់សសរចាប់ពីផ្នែកម្រាលទៅ មានទំហំ មុខកាត់200x200mm។

## ២-២-ការជីកដី និង ការរៀបចំទ្រនាប់គ្រឹះ

ការជីកដីសម្រាប់គ្រឹះទាំងអស់ត្រូវមានទំហំយ៉ាងហោច ១២០០x១២០០មម សម្រាប់អគារមាន នីវ៉ូផ្ទាល់ដី និង ១៦០០x ១៦០០មម សម្រាប់អគារមានខឿនផុតពីដី ជាមួយនឹងជំរៅ១៥៥០មម។ ចំណែកការលកដីសម្រាប់ធ្នឹមគ្រឹះមានមាត់ចង្អូរ ៤០០មម និង ជម្រៅ ៣០០មម ពីនីវ៉ូដីធម្មជាតិ។ ចំពោះទំហំថ្មសម្រាប់បង្ហាប់ធ្វើទ្រនាប់គ្រឹះមានទំហំ 40x60មម ។ស្រទាប់បង្ហាប់ថ្មមានកម្រាស់ តិចបុះផុត ១០០មម ។ ការងាររៀបចំទ្រនាប់គ្រឹះចាំបាច់ធ្វើឡើងគោរពតាមប្លង់លំអិត។

## ២-៣-បេតុងជើងតាង

ជើងតាងត្រូវធ្វើពីបេតុងអាម៉េ ដែលមានបង្ហាញនៅក្នុងប្លង់លម្អិត។ កម្រាស់បេតុង អប្បបរិមា សម្រាប់ស្រទាប់ការពារគឺ៥សម។ ដែកជើងតាង និងកំណល់ចាំបាច់ត្រូវដាក់ ក្រោយពីសំអាត ផ្ទៃស្រទាប់ការពារឲ្យបានស្អាត ចំណែកការងារចាក់បេតុងចាំបាច់ត្រូវធ្វើ នៅពេលវាយក្តារពុម្ព និងដាក់ដែករួចដោយមានការពិនិត្យត្រឹមត្រូវពីវិស្វករ។ ការងារចាក់ បេតុងចាំបាច់ត្រូវប្រើម៉ាស៊ីន រំញ័រដើម្បីបង្ហាប់ ផ្ទៃជើងតាងឲ្យបានហាប់ស្មើល្អ។

## ២-៤-ពុម្ពឈើសម្រាប់ធ្វើគ្រឹះ

ការចាក់បេតុងគ្រឹះទាំងអស់ត្រូវតែប្រើក្តារពុម្ពឲ្យបានត្រឹមត្រូវគ្រប់ជ្រុង ដើម្បីធានាឲ្យបាននូវ គុណភាពបេតុងល្អ កម្ពស់ជើងតាងបានត្រឹមត្រូវ និងផ្ទៃនៃជ្រុងនីមួយៗស្មើល្អ ជៀសវាងការ ជ្រាបទឹកស៊ីម៉ង់តិចូលក្នុងដីដែលបណ្តាលឲ្យបេតុងមានគុណភាពមិនល្អ។

**៣-ជញ្ជាំងទប់ដី**
ជញ្ជាំងទប់ដីត្រូវសង់ដោយប្រើឥដ្ឋតាន់ឌុប(២០ស.ម) តាមប្លង់លំអិតបច្ចេកទេស។ នីវ៉ូនៃជញ្ជាំងទប់ដីរៀបដល់នីវ៉ូមាន២៥០មមទាបជាងនីវ៉ូនៃកម្រាលបេតុង(0,00)។បាតគ្រឹះត្រូវធ្វើឲ្យបាន រាបស្មើសម្រាប់ជាគ្រឹះនៃជញ្ជាំងទប់ ដីជុំវិញអគារតាមបរិមាណនៃអគារ ។ បាតគ្រឹះសម្រាប់រៀបជញ្ជាំងទប់ដីត្រូវសង់នៅលើស្រទាប់បេតុងថ្មបង្ហាប់ ។ បេតុងថ្មត្រូវ មានទំហំ ៥០មម x៦០មម។ កម្រាស់អប្បបរិមានៃស្រទាប់បេតុងថ្មបង្ហាប់គឺ ១៥០មម។បេតុងសំអាតផ្ទៃ មានកម្រាស់៣០មម។ ស្រទាប់និមួយៗរៀបចំឡើងតាមប្លង់លំអិត។

**៤-ការចាក់ដីបំពេញ** (**ពិនិត្យលក្ខខ័ណ្ឌបច្ចេកទេសនៅក្នុងប្លង់លំអិត**)
ដីដែលត្រូវការឲ្យចាក់បំពេញដើម្បីតំឡើងខឿន កម្រាល គឺ ជាដីដែលមានល្បាយ ខ្សាច់។ ត្រូវគាស់សម្អាតរុក្ខជាតិឲ្យអស់ ចេញពីកន្លែងដែលត្រូវចាក់ដីបំពេញឲ្យបានមុនពេលចាប់ផ្តើមការងារ។ ដីដែលត្រូវយកមកចាក់បំពេញនោះក៏មិនត្រូវឲ្យមានរុក្ខជាតិ ឬ ក៏កំទេចកំទីអ្វីផ្សេងៗឡើយ។ ដីចាក់បំពេញត្រូវចាក់តាមស្រទាប់ដោយមិនឲ្យក្រាស់ជាង ១៥ស .ម មុនពេល បង្ហាប់ចាំបាច់ផ្សើមទឹកជាមុន។ ក្រោយពេលដែលបុកបង្ហាប់ស្រទាប់ដី ទីមួយរួចហើយ ពេលនោះ ទើបភាគីទទួលការងារម៉ៅការ អាចចាក់បំពេញដីមួយស្រទាប់ទៀត ។ ទង្វើនេះត្រូវធ្វើរហូតដល់ទទួលបានកម្រាស់ដីដែលចង់បាន។ ចំពោះអាចម៍ដី ដែលយកមកចាក់បំពេញត្រូវធានាថាមិនមានបញ្ហា UXO។

**៥-ស្រទាប់គ្រឹះក្រោមកម្រាលបេតុង**(**សម្រាប់អគារខឿន ១,៥០ម និង តូចជាង**)
ស្រទាប់គ្រឹះក្រោមកម្រាលបេតុងគឺជាស្រទាប់បេតុងថ្មបង្ហាប់។បេតុងថ្មត្រូវមានទំហំ ៥០x៦០ម.ម កម្រាស់អប្បបរិមានៃស្រទាប់ថ្មបង្ហាប់គឺ ១៥០មម ។ បេតុងសំអាតផ្ទៃ មានកម្រាស់ ៣០មម។ការងារបង្ហាប់ស្រទាប់ថ្មត្រូវមាននីវ៉ូ ១០០មម ទាបជាងនីវ៉ូកម្រាលស្អាតរួចរាល់។ ការងារបង្ហាប់ថ្មត្រូវផ្អែកលើគំនូរប្លង់លំអិត។

**៦-ធ្នឹមគ្រឹះ** (**២០០**x **២៥០**)**មម** (**សម្រាប់ខឿន ១,៥០ម និង តូចជាង**)
ធ្នឹមកម្រាលត្រូវធ្វើពីបេតុងអាម៉េហើយមានមុខកាត់២០០មមx២៥០មម។សរសៃដែកត្រូវដំឡើងឲ្យបានត្រឹមត្រូវតាមការលម្អិតក្នុងគំនូសប្លង់។ ការតដែកត្រូវដាក់ជ្រួសគ្នា ឲ្យបានប្រវែងតិចបំផុត ៦០០មមនិង៥០០មមសម្រាប់ដែកទទឹង ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់២៥មម។ មុនធ្វើការងារចាក់បេតុងក្រុមហ៊ុនសាងសង់ត្រូវមានការឯកភាពពីវិស្វករជាមុន ដោយមានលិខិតស្នើសុំចាក់បេតុងចំនួន០៧ ថ្ងៃមុនដល់ថ្ងៃកំណត់ចាក់បេតុង។

**៧-ធ្នឹមគ្រឹះ (២០០x៣០០មម)(សម្រាប់ខឿន ធំជាង១,៥០ម)**

ធ្នឹមគ្រឹះត្រូវធ្វើពីបេតុងអាម៉េ ហើយមានមុខកាត់ ២០ ០មមx៣០០មម។ សរសៃដែកត្រូវ ដំឡើងឲ្យបានត្រឹមត្រូវតាមការលម្អិតក្នុងគំនូសប្លង់។ សរសៃដែកត្រូវដាក់ដូចក្នុងប្លង់ដែលផ្តល់ឲ្យដោយឡែក ដោយនាយកដ្ឋានសំណង់ ក្រសួងអប់រំ យុវជន និងកីឡា។ ការតដែកត្រូវដាក់ជ្រួសគ្នាឲ្យបានប្រវែងតិចបំផុត ៦០ ០មម ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់២៥មម ។ មុនធ្វើការងារចាក់បេតុងក្រុមហ៊ុនសាងសង់ត្រូវមានការឯកភាពពីវិស្វករជាមុនដោយមានលិខិតស្នើសុំចាក់បេតុងចំនួន០៧ថ្ងៃមុនដល់ថ្ងៃកំណត់ចាក់បេតុង ។ កាងារចងដែក និងទំហំដែក ត្រូវមានកាអនុញ្ញត្តិពីវិស្វករការដ្ឋាន និងក្រសួងអប់រំ យុវជន និងកីឡាមុននឹងចាក់បេតុង។

**៨-ធ្នឹមទ្រប្លង់សេ (២០០x៣០០មម)(សម្រាប់ខឿនធំជាង១,៥ម)**

ធ្នឹមកម្រាលត្រូវធ្វើពីបេតុងអាម៉េ ហើយមានមុខកាត់ ២០ ០មមx៤០០មម។ សរសៃដែក ត្រូវដំឡើងឲ្យបានត្រឹមត្រូវតាមការលម្អិតក្នុងគំនូសប្លង់ ដែលផ្តល់ដោយនាយកដ្ឋានសំណង់ ក្រសួងអប់រំយុវជននិងកីឡា។ការតដែកត្រូវដាក់ជ្រួសគ្នាឲ្យបានប្រវែងតិចបំផុត៦០០មម។ស្រទាប់បេតុង ការពារដែកត្រូវមានកម្រាស់២៥មម ។ ក្រុមហ៊ុនសាងសង់ត្រូវមានការឯកភាព ពីវិស្វករជាមុនដោយមានលិខិតស្នើសុំចាក់បេតុងចំនួន០៧ថ្ងៃមុនដល់ថ្ងៃកំណត់ចាក់បេតុង ដើម្បីឲ្យមានការឯកភាពជាមុនលើការងាររៀបចំសរសៃដែក និងក្តារពុម្ព។

**៩-ធ្នឹមទ្រប្លង់សេ (២០០x៤០០មម)(សម្រាប់ខឿនធំជាង១,៥ម)**

ធ្នឹមកម្រាលត្រូវធ្វើពីបេតុងអាម៉េ ហើយមានមុខកាត់ ២០ ០មមx៤០០មម។ សរសៃដែក ត្រូវដំឡើងឲ្យបានត្រឹមត្រូវតាមការលម្អិតក្នុងគំនូសប្លង់ ដែលផ្តល់ឲ្យដោយឡែកដោយនាយកដ្ឋានសំណង់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។ ការតដែកត្រូវដាក់ជ្រួសគ្នាឲ្យបានប្រវែងតិចបំផុត៦០០មម។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់២៥មម ។ ក្រុមហ៊ុន ត្រូវជូនដំណឹងដល់វិស្វករការដ្ឋាន និងវិស្វករនាយកដ្ឋានសំណង់ ដោយមានលិខិតស្នើសុំចាក់បេតុងចំនួន០៧ថ្ងៃមុនដល់ថ្ងៃកំណត់ចាក់បេតុង ។ ការចងដែក និងទំហំដែកត្រូវមានការ អនុញ្ញត្តិ ពីវិស្វករការដ្ឋាន និងវិស្វករក្រសួងមុននឹងចាក់បេតុង។

**១០-បេតុងអារមេប្លង់សេកម្រាល (សម្រាប់ខឿន ១,៥០ម និង តូចជាង)**

ប្លង់សេកម្រាលត្រូវធ្វើពីបេតុងអាម៉េ ហើយមាន កម្រាស់ ៦០មម ។ ការងារព្រងាយសរសៃដែកជាប្រភេទដែកមូលមានអង្កត់ផ្ចិត ៨មម ដែលវែងជាក្រឡា ១៥០មម x១៥០មម ទាំងពីរទិស។ សរសៃដែកត្រូវដំឡើងឲ្យបានត្រឹមត្រូវតាមការលម្អិតក្នុងគំនូសប្លង់ ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់២៥មម ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់២៥មម។ផ្ទៃកម្រាលបេតុងត្រូវធានាបាននូវភាពស្មើរលោង ។ ដើម្បីការពារកម្រាលឲ្យរលោង កម្រាលត្រូវចាក់នៅពេល

ណាគ្រឿងបង្គំចាក់រួច ប្រក់ដំបូលរួច និងបូករួច ។ ក្រុមហ៊ុនសាងសង់ត្រូវមានការឯកភាពពីវិស្វករជាមុនដោយមានលិខិតស្នើសុំចាក់បេតុងចំនួន០៧ថ្ងៃមុនដល់ថ្ងៃកំណត់ចាក់បេតុងដើម្បីឲ្យមានការឯកភាពជាមុនលើការងាររៀបចំសរសៃដែក និង ក្តារពុម្ព។

## ១១-បេតុងអារមេប្លង់សេកម្រាល (សម្រាប់ខឿន ២,៥0ម និង ធំជាង)

ប្លង់សេកម្រាលត្រូវធ្វើពីបេតុងអាម៉េ ហើយមានកម្រាស់ ១០០មម ។ ការងារព្រងាយសរសៃដែកជាប្រភេទដែកមូលមានអង្កត់ផ្ចិត ៨មម ដែលវែងជាក្រឡា ១០០មម x១០០មម ទាំងពីរទិស។ សរសៃដែកត្រូវដំឡើងឲ្យបានត្រឹមត្រូវតាមការលម្អិតក្នុងគំនូសប្លង់ ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់២៥មម។ផ្ទៃកម្រាលបេតុងត្រូវធានាបាននូវភាពស្មើរលោង។ ក្រុមហ៊ុនសាងសង់ត្រូវមានការឯកភាពពីវិស្វករជាមុនដោយមានលិខិតស្នើសុំចាក់បេតុងចំនួន០៧ថ្ងៃមុនថ្ងៃកំណត់ចាក់បេតុងដើម្បីឲ្យមានការឯកភាពជាមុនលើការងាររៀបចំសរសៃដែក និង ក្តារពុម្ព។

## ១២-សសរបេតុងអារម៉េ

សសរមានពីរប្រភេទត្រូវធ្វើពីបេតុងអាម៉េ ដែលមានទំហំ២០០មមx២០០មម ។ ដែកសរសៃសម្រាប់ធ្វើសសរត្រូវតំឡើងឲ្យ ដូចក្នុងប្លង់លម្អិត ដែលផ្តល់ដោយនាយកដ្ឋានសំណង់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។ ដែកសម្រាប់ធ្វើសសរត្រូវតជ្រួសមុខគ្នាទៅនឹងដែកសសៃចេញពីជើងតាង ឲ្យបានប្រវែងអប្បបរិមា៣០០ម។ ត្រូវទុកចំរឹងដែកសសៃប្រវែងអប្បបរិមា៦០០មម ចេញពីចុង សសរសម្រាប់តធ្នឹមក្រវ៉ាត់លើ ជញ្ជាំងនៅពេលក្រោយ។ ក្រោយពេលចាក់បេតុងហើយត្រូវពិនិត្យប្រយោលឡើងវិញទុកឈើទល់និងពុម្ពឈើនៅនឹងកន្លែងដោយគ្មានការប៉ះពាល់ឲ្យបានរយៈពេលយ៉ាងតិចចំនួន៤ថ្ងៃ ។ សសៃដែកទប់តដ្ឋជញ្ជាំងត្រូវដាក់រាយស្មើចូលក្នុងសសរឲ្យបានចន្លោះពីដែកមួយទៅដែកមួយស្មើនឹង៤០០មតាមបណ្តោយនៃកម្ពស់សសរ ។ សសៃដែកទប់តដ្ឋជញ្ជាំងត្រូវមានទំហំ៦មម ហើយទុកឲ្យលៀនចេញពីមុខសសរប្រវែងអប្បបរិមា៥០០មម។ស្រទាប់ បេតុងការពារដែកសសរត្រូវមានកម្រាស់ ២៥មម។ ត្រូវដាប់ផ្ទៃបាតរបស់សសរបេតុងដែលត្រូវសង់ ដើម្បី ឲ្យមានផ្ទៃគ្រើមសម្រាប់មុខតំណសសរបេតុងឲ្យបានជម្រៅយ៉ាងតិច១៥មមមុននឹងដាក់ដំឡើងដែក និងពុម្ពឈើ ។

## ១៣-ធ្នឹមលើ

ការងារធ្វើធ្នឹមទាំងអស់ត្រូវចាប់ផ្តើមអនុវត្ត ក្រោយពីការងាររៀបជញ្ជាំងបានរៀបចំរួច។មុននឹងធ្វើការងារចាក់បេតុងក្រុនហ៊ុនសាងសង់ត្រូវមានលិខិតស្នើចាក់បេតុងចំនួន០៧ថ្ងៃ មុនថ្ងៃចាក់ ។ ចំពោះការងារពង្រាយសរសៃដែក និងទំហំខ្នាតពុម្ពត្រូវមានការឯកភាពពីវិស្វករជាមុន។ការងាររៀបចំពុម្ព និង ការងារពង្រាយសរសៃដែកត្រូវផ្អែកលើប្លង់លំអិតបច្ចេកទេស ដែលជាឯកសារដាច់ដោយឡែករបស់ក្រសួងអប់រំ យុវជន និងកីឡា។

**១៣,១-ធ្នឹមមេទទឹងបន្ទប់** (**ទំហំ ២០០មម** x **៤០០ម.ម**)

ធ្នឹមនេះត្រូវធ្វើពីបេតុងអាម៉េដែលមានទំហំមុខកាត់២០០មមx៤០០មម ។ សរសៃដែកធ្នឹមត្រូវតម្លើងឲ្យដូចក្នុងប្លង់លម្អិតបច្ចេកទេសរបស់នាយកដ្ឋានសំណង់ ។ ការតដែកត្រូវដាក់គងគ្នាឲ្យបានប្រវែងតិចផុត៦០០មមបណ្ដោយ និង៤០០មមសម្រាប់ដែកទទឹង ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់ ២៥មម។

**១៣,២-ធ្នឹមក្រវ៉ាត់កាត់ទទឹងបន្ទប់លើជញ្ជាំងខ័ណ្ឌ** (**ទំហំ ២០០មម** x **២០មម**)

ធ្នឹមនេះត្រូវធ្វើពីបេតុងអាម៉េដែលមានទំហំមុខកាត់២០០មមx២០០មម។សរសៃដែកធ្នឹមត្រូវតម្លើងឲ្យដូចក្នុងប្លង់លម្អិតបច្ចេកទេសរបស់នាយកដ្ឋានសំណង់ ។ ការតដែកត្រូវដាក់គងគ្នាឲ្យបានប្រវែងតិចផុត ៦០០មមបណ្ដោយ និង៤០០មមសម្រាប់ដែកទទឹង ។ ស្រទាប់បេតុង ការពារដែកត្រូវមានកម្រាស់ ២៥មម។

**១៣,៣-ធ្នឹមក្រវ៉ាត់ទិសដៅបណ្ដោយ** (**ទំហំ ២០០មម** x **២០០មម**)

ធ្នឹមនេះត្រូវធ្វើពីបេតុងអាម៉េដែលមានទំហំមុខកាត់ ២០ ០មមx២០០មម ។ សរសៃដែកធ្នឹមត្រូវតម្លើងឲ្យដូចក្នុងប្លង់លម្អិតបច្ចេកទេសរបស់នាយកដ្ឋានសំណង់ ។ ការតដែកត្រូវដាក់គងគ្នាឲ្យបានប្រវែងតិចផុត ៦០០មមបណ្ដោយ និង៤០០មមសម្រាប់ដែកទទឹង ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់ ២៥មម។

**១៤-ធ្នឹមបេតុងអាម៉េទ្រដំបូល** (**ទំហំ ១៥០មម**x**២៥០មម**)

ធ្នឹមនេះត្រូវធ្វើអំពីបេតុងអាម៉េដែលមានទំហំមុខកាត់ ១៥០មម x២៥០មម ។ ដែកសរសៃសម្រាប់ ធ្នឹមត្រូវតម្លើងឲ្យដូចក្នុងប្លង់លម្អិត របស់នាយកដ្ឋានសំណង់ ក្រសួងអប់រំ យុវជន និងកីឡា។ ការតដែកត្រូវដាក់គងគ្នាឲ្យបានប្រវែងតិចបំផុត ៦០០មមបណ្ដោយ និង៤០០មមទទឹង ។ ស្រទាប់បេតុងការពារដែលត្រូវមានកម្រាស់២៥មម។ ក្រុមហ៊ុនសាងសង់ត្រូវធ្វើសំណើសុំចាក់បេតុងជាលាយល័ក្ខអក្សរ៧ថ្ងៃមុននឹងដល់ថ្ងៃចាក់បេតុង ដើម្បីទទួលការត្រួតពិនិត្យនិងឯកភាពពីវិស្វករប្រចាំការដ្ឋាននិងវិស្វករក្រសួង។

**១៥-ឡាំងតូលើទ្វារ បង្អួច និងឡាំងតូក្រោមបង្អួច** (**ទំហំ ១០០មម**x**២០០មម**)

ឡាំងតូទាំងនេះត្រូវធ្វើពីបេតុងអាម៉េដែលមានទំហំមុខកាត់ ១០ ០មមx២០០មម ។ ដែកសសៃសម្រាប់ធ្វើធ្នឹមត្រូវប្រើដែកថ្នាំងអំពៅមានអង្កត់ផ្ចិត ១២មម ឡើងទៅ។ ការត ដែកត្រូវដាក់ជ្រួសមុខគ្នាឲ្យបានប្រវែងតិចបំផុត ៥០០មម ។ ស្រទាប់បេតុងការពារដែកត្រូវមានកម្រាស់ ២៥មម។ ដែកសសៃត្រូវតម្លើង ឲ្យដូចប្លង់លម្អិតរបស់នាយកដ្ឋានសំណង់ ក្រសួងអប់រំ យុវជន និងកីឡា។

## ១៦-ឡាំងតូក្រោមបង្អួច (ទំហំ ១០០មម x២០០មម)

ឡាំងតូទាំងនេះត្រូវធ្វើពីបេតុងអាម៉េដែលមានទំហំមុខកាត់ ១០ ០មមx២០០មម ។ ដែកសសៃសម្រាប់ធ្វើធ្នឹមត្រូវប្រើដែកថ្នាំងអំពៅមានអង្កត់ផ្ចិត ១២មម ឡើងទៅ។ ការតដែកត្រូវដាក់ជ្រួសមុខគ្នាឲ្យបានប្រវែងតិចបំផុត ៥០ ០មម។ ស្រទាប់បេតុងការពារដែក ត្រូវមានកម្រាស់២៥មម។ ដែកសសៃត្រូវតម្លើងឲ្យដូចប្លង់លម្អិត។ឡាំងតូក្រោមបង្អួចត្រូវបណ្តុះដែកដូចក្នុងប្លង់លម្អិត ដើម្បីចាក់បេតុងថែងគ្រោងបង្អួច ទ្វារ ទាំងបួនជ្រុង ដូចបង្ហាញក្នុងប្លង់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## ១៧-បាំងសាចលើបង្អួច

បង្អួចខាងក្រោយអគារ ត្រូវដាក់បាំងសាចបេតុងអាម៉េដែលមានទទឹង ៦០០មម បណ្តោយ ២៥០០មម និងកម្រាស់៦០មម ហើយត្រូវសង់ទៅតាមប្លង់លម្អិតដែលបានបង្ហាញ។ ការចាក់បេតុងបាំងសាច(អូវ៉ង់) និងធ្នឹមឡាំងតូផ្នែកខាងលើនៃបង្អួច ចាំបាច់ត្រូវធ្វើឡើងដំណាលគ្នាក្នុងពេលតែមួយ។

## ១៨-បេតុងកម្រាលជុំវិញអគារ

គ្រឹះសម្រាប់កម្រាលបេតុងជុំវិញអគារ ជាស្រទាប់បេតុងថ្ម មាន កម្រាស់ ៣០មម។ កម្រាលកម្រាលជុំវិញអគារត្រូវធ្វើពីបេតុងដែលមាន ទទឹង ១០០០មម ពីជញ្ជាំងអគារ ។កម្រាលបេតុងជុំវិញអគារត្រូវមានផ្ទៃរាបស្មើ ហើយរលោង និងត្រូវមានមុំជម្រាល៣ដឺក្រេ ដើម្បីឱ្យទឹកហូរចេញពីជញ្ជាំង។ កម្រាលបេតុងត្រូវសង់ឲ្យដូចប្លង់លម្អិតរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ១៩-គុណភាពនៃការចារបេតុង និង ការថែទាំបេតុង

ចំពោះគ្រឿងបង្គុំបេតុងអារមេទាំងឡាយណា ដែលធ្វើឡើងពីដែកមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងមានទំហំមុខកាត់មិនត្រឹមត្រូវតាមប្លង់ចាំបាច់ត្រូវវាយចោលនិងសាងសង់ថ្មី។ផ្ទៃកម្រាលបេតុងត្រូវបញ្ចប់ដោយមានភាពស្មើល្អ គ្មានចំនុចទាបខ្ពស់។សសរបេតុអារមេទាំងអស់ត្រូវមានភាពត្រង់ និងរត់ត្រង់ជ្ញរ។ធ្នឹមបេតុងអារមេត្រូវរត់ត្រង់ជ្ញរក្នុងទិសដៅផ្តេកនិងត្រង់ស្មើល្អ។ ក្តារពុម្ពចាំបាច់ធានាមិនឲ្យមានភាពកោង និងរមួល។ កម្លាំងរ៉េស៊ីស្តង់នៃបេតុង មិនត្រូវតិចជាង ២០០Kg/cm2។

## ២០-ជញ្ជាំងឥដ្ឋនៅចន្លោះសសរ

ត្រូវសង់ជញ្ជាំងឥដ្ឋដប់ (ឥដ្ឋ១០) នៅចន្លោះសសរ។ ជញ្ជាំងខ័ណ្ឌត្រូវរៀបឲ្យដល់ដំបូល។ ការរៀបឥដ្ឋត្រូវភ្ជាប់ដោយបាយអរដែលមានកម្រាស់ ១៥មម។ ជញ្ជាំងមួយនៅខាងចុងនៃអគារ

ដូចមានបង្ហាញនៅក្នុងប្លង់របស់ក្រសួងអប់រំ យុវជន និង កីឡាគឺរៀបចំឡើងដោយឥដ្ឋខុប (២០សម) ការងាររៀបជញ្ជាំងឥដ្ឋខុបនេះត្រូវរៀបរហូតដល់បាតធ្នឹមកាត់ទទឹងត្រង់ជញ្ជាំង ខ័ណ្ឌនោះ ។ ជញ្ជាំងឥដ្ឋទាំងរៀបឡើងដោយភ្ជាប់នឹងសរសៃដែកបណ្ដុះចេញពីសសរក្នុងចន្លោះ ៤០០មមមួយតាមបណ្ដោយសសរ។ ការងាររៀបជញ្ជាំងត្រូវមានភាពត្រង់និងស្មើល្អក្នុងផ្ទៃជញ្ជាំងទិសដៅបញ្ឈរ។ការងាររៀបឥដ្ឋត្រូវធ្វើឡើងដោយជាងមានជំនាញច្បាស់លាស់ ។ សម្រាប់បំពេញល្បាយបេតុងកម្រាលចូលក្រោមផ្ទៃជញ្ជាំងនៅស្រទាប់ក្រោមចាំបាច់រៀបដោយឥដ្ឋតាន់និងទុកចន្លោះមួយរំលងមួយនៃគ្រប់ជញ្ជាំងខ័ណ្ឌទាំងអស់។

## ២១-ឥដ្ឋ

ឥដ្ឋត្រូវមានគុណភាពលេខ១ និងភាពធន់ខ្ពស់ ហើយជាឥដ្ឋដែលធ្វើពីដីឥដ្ឋដុតមិនខ្លោច មិនឆៅ។ ឥដ្ឋត្រូវមានទ្រង់ទ្រាយត្រឹមត្រូវហើយមានទំហំ ៩០មម x៩០មមx១៩០មម ចំពោះឥដ្ឋប្រហោង និងទំហំ៤៥មមx៩០មមx១៩០មម ចំពោះឥដ្ឋតាន់។ ប្រសិនបើយើងរកឃើញថាកន្លែងណាមួយមានដាក់ឥដ្ឋគុណភាពអន់ យើងមិនអាចទទួលយកបានទេ ហើយត្រូវរុះរើ និងសង់ថ្មីដោយភាគីទទួល ការងារមៅការ។

## ២២-ប្លុកឥដ្ឋខ្យល់

ឥដ្ឋខ្យល់ត្រូវចាក់ពុម្ពឡើងតាមសមមាមាត្រល្បាយ 1:3 ដោយស៊ីម៉ង់មួយភាគ និងខ្សាច់៣ភាគ។ខ្សាច់ត្រូវស្អាតគ្មានកំទេចកំទីសំរាម និងគ្មានល្បាយដីលើសកំណត់។ ក្រោយបកចេញពីពុម្ពត្រូវរៀបចំកន្លែងដាក់តំរៀបដោយក្រាលខ្សាច់និងផ្សើមទឹក និងគ្រប ថងផ្លស្ទីចចំនួន០៣ថ្ងៃ។

## ២៣-ការងារបូកសម្អាតសសរ និង ធ្នឹម

ការងារបូកទាំងអស់ត្រូវអនុវត្តដោយជាងមានជំនាញខាងបូកបាយអរ ។ ផ្ទៃបូកទាំងអស់ត្រូវតែរាបស្មើនិងត្រង់ជានិច្ច។បើសិនជាយើងរកឃើញថា កន្លែងណាមួយមិនរាបស្មើ និងមានស្រទាប់បាយអរស្តើងគុណភាពអន់យើងមិនទទួលយកហើយភាគីទទួលការងារមៅការត្រូវធ្វើឡើងវិញ។ល្បាយបេតុងលាយលើស៣០នាទីមិនអនុញ្ញាតឲ្យប្រើប្រាស់ក្នុងការងារបូកទេ ។ ការងារបូកចាំបាច់លាយល្បាយបេតុងដោយម៉ាស៊ីនក្នុងកំរិតល្មមដែលនឹងអាចជាតម្រូវការក្នុងការងារបូក។កម្រាស់ស្រទាប់បាយអរបូកគឺ តិចបំផុត ២០មម។ការងារបូកត្រូវធ្វើឡើងពីរស្រទាប់ ដែលមានកម្រាស់ជារួម២០មម ។ ក្រោយបូកសំអាតរួចរាល់ហើយជញ្ជាំងទាំងនេះត្រូវផ្តល់សំណើមបាញ់ទឹកក្នុងមួយថ្ងៃ២ដង ដើម្បីធានាបាននូវការប្រេះ។

## ២៤-ការងារបូកសម្អាតជញ្ជាំង

ការងារបូកទាំងអស់ត្រូវអនុវត្តដោយជាងមានជំនាញខាងបូកបាយអរ ។ ផ្ទៃបូកទាំងអស់ត្រូវតែរាបស្មើនិងត្រង់ជានិច្ច ។ កម្រាស់ស្រទាប់បាយអរបូកគឺ តិចបំផុត ២០មម។ បើសិនជាយើងរកឃើញថា កន្លែងណាមួយមិនរាបស្មើ និងមានស្រទាប់ បាយអរស្តើង គុណភាពអន់ យើងមិនទទួលយកហើយភាគីទទួលការងារមៅការត្រូវ ធ្វើឡើងវិញ។ ល្បាយបេតុងលាយលើស៣០នាទីមិនអនុញ្ញាតឲ្យប្រើប្រាស់ក្នុងការងារបូកទេ។ការងារបូកចាំបាច់លាយល្បាយបេតុងដោយម៉ាស៊ីនក្នុងកំរិតល្មមដែលនឹងអាចជាតម្រូវការក្នុងការងារបូក។ ការងារបូកត្រូវធ្វើឡើងពីរស្រទាប់ ដែលមានកម្រាស់ជារួម២០មម ។ ក្រោយបូកសំអាតរួចរាល់ហើយជញ្ជាំងទាំងនេះត្រូវផ្តល់សំណើមបាញ់ទឹកក្នុងមួយថ្ងៃ២ដង ដើម្បីធានាបាននូវការប្រេះ។

## ២៥-ការតំឡើងគ្រឿងដំបូលដែក

គ្រឿងដំបូលដែលធ្វើអំពីដែកត្រូវសង់ឲ្យដូចប្លង់លម្អិត ដែលផ្តល់ដោយនាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា ។ ផ្ទោងរយជាប្រភេទដែក សេ មានទំហំ ១០០មម x៥០មម និងកម្រាស់ ២,៣មម ។ ចន្លោះពីផ្ទោងមួយទៅផ្ទោងមួយទៀតគឺ ៨០០មម ហើយជម្រាលនៃដំបូលគឺ មុំ ២៩ដឺក្រេ ហើយផ្ទោងត្រូវផ្សារភ្ជាប់ដោយបន្សាអគ្គីសនី។ ដែរណែង ជាប្រភេទដែកអិល(L) មានទំហំ ២៥មម x២៥មម និង មានកម្រាស់ ៣មម។ ចន្លោះពីដែរណែងមួយទៅដែរណែងមួយទៀតគឺ៣៨០មម(ក្បឿងភ្លឺធំ) និង២៤០មម (ក្បឿងក្បាច់)។ គ្រឿងបង្គុំដែកដំបូលអគារទាំងមូលត្រូវលាបថ្នាំការពារច្រែះមួយស្រទាប់ដំបូងនៅលើផ្ទៃដែកទាំងអស់ មុននឹងលាបថ្នាំប្រេងពណ៌ប្រផេះចំនួនពីរស្រទាប់ថែមពីលើទៀត ។ រាល់ចំនុចផ្សារនៃគ្រឿងបង្គុំដែកដំបូលដែលផ្សាររួចត្រូវលាបថ្នាំឡើងវិញមុនពេលប្រក់ក្បឿង ។ អ្នកមៅការត្រូវជូនដំណឹងមកវិស្វករការដ្ឋាន និងវិស្វករក្រសួងឲ្យបាន៧ថ្ងៃមុនមុននឹងដាក់ដែក ដំបូល។ ប្រភេទដែក និងទំហំត្រូវមានការអនុញ្ញត្តិពីវិស្វករការដ្ឋាន និងវិស្វករក្រសួងមុននឹងនឹងដំឡើងគ្រោងដំបូល។

## ២៦-គុណភាពក្បឿង

ក្បឿងប្រក់ដំបូលត្រូវមានគុណភាពលេខ១ ធ្វើពីបាយអរ សង្កត់ដោយម៉ាស៊ីន ហើយមានទំហំប៉ុនៗគ្នា។ គែម និងជ្រុងនៃក្បឿងទាំងអស់ត្រូវឲ្យត្រង់ស្មើ និង គ្មានទឹករលក។ ភាគីទទួលការងារមៅការ ត្រូវដាក់គំរូក្បឿង ដើម្បីឲ្យភាគីប្រគល់ការងារអនុម័ត។ ក្បឿងដែល ត្រូវប្រើក្នុងសំណង់ត្រូវឲ្យដូចគ្នាទៅនឹងប្រភេទក្បឿងដែលបានបង្ហាញឲ្យ ភាគីប្រគល់ការងារ អនុម័ត។ ក្បឿងដែលយកឲ្យភាគីប្រគល់ការងារអនុម័ត ត្រូវមានម៉ាក យីហោច្បាស់លាស់។

**២៧-ទ្វារ**(**ឈើ**)

ទ្វារត្រូវសង់ទៅតាមគំរូដូចដែលបានបង្ហាញនៅក្នុងប្លង់លម្អិត ដែលបានផ្តល់ដោយនាយកដ្ឋានសំណង់ នៃក្រសួងអប់រំ យុវជន និងកីឡា ។ ទ្វារត្រូវធ្វើអំពីឈើ ដែលមាន គុណភាពលេខ១ គឺ ឈើប្រភេទ ដូងថែម គគីរ ធ្នង់ ធ្នឹក ស្រឡៅ និង សុក្រំ។ ត្រណាប់តាមកែងត្រូវដាប់ឲ្យត្រង់សម្រាប់ដាក់ពន្លួញនិងវាយកន្លាស់ឈើហើយដែកកែងទ្វារ ត្រូវដាក់ឲ្យអឺប ទៅនឹងផ្ទៃសាច់ឈើ និង មូលវីសទំហំ ៣០មម ចូលទៅក្នុងសាច់ឈើ។ កន្លាស់តំណដ៏ទៃទៀតរវាងពន្លួញទ្វារ និង ត្រណាប់ត្រូវតភ្ជាប់គ្នាដោយប្រើកន្លាស់ឈើរាងការ៉េ ហើយតឹង ណែន ជានិច្ច។ ឈើដែលប្រើសម្រាប់ធ្វើទ្វារត្រូវហាលឲ្យស្ងួតយ៉ាងតិច ៤៥ថ្ងៃ មុនពេលយកទៅប្រើ។ ដៃកាន់បិទបើកទ្វារ ត្រូវដាក់ក្នុងកម្ពស់ ១០០០មម។ ទ្វារនីមួយៗត្រូវមានសោរមួយ និង ដៃកាន់បិទបើកទ្វារ។ ដៃកាន់បិទបើកទ្វារត្រូវធ្វើពីដែកក្រូម៉េ។ រនុកទ្វារត្រូវដាក់នៅផ្នែកខាងលើ និង ខាងក្រោមនៃសន្លឹកទ្វារ ខាងឆ្វេង ។

**២៨-បង្អួច**(**ឈើ**)

បង្អួចត្រូវសង់ទៅតាមគំរូដូចដែលបានបង្ហាញនៅក្នុងប្លង់លម្អិត។ បង្អួចត្រូវធ្វើអំពីឈើ ដែលមាន គុណភាពលេខ១ ដូចឈើធ្វើទ្វារដែរ។ កន្លាស់តំណកែងបង្អួច គឺ ត្រូវមានរាងការ៉េធ្វើពី ឈើ។ កែងដែកបង្អួចត្រូវតំឡើងឲ្យស្មើទៅនឹងផ្ទៃសាច់ឈើ ហើយមូលភ្ជាប់ដោយប្រើវីសទំហំ ៣០មម ពន្លិចចូលក្នុងសាច់ឈើ។ កន្លាស់ដទៃទៀតរវាងពន្លួញបង្អួច និងត្រណាប់ត្រូវតភ្ជាប់គ្នា ដោយប្រើកន្លាស់ឈើរាងការ៉េ ហើយតឹងណែនជានិច្ច។ ឈើប្រើសម្រាប់ធ្វើបង្អួចត្រូវហាលឲ្យស្ងួតយ៉ាងតិច ៤៥ថ្ងៃ មុនពេលយកទៅធ្វើ។ សន្លឹកទ្វារបង្អួចត្រូវឲ្យមានដៃចាប់ទាញ និង ធ្វើពីដែកក្រូម៉េ។ រនុកបង្អួចត្រូវដាក់នៅផ្នែកខាងលើ និង ផ្នែកខាងក្រោមនៃបង្អួច។ ត្រូវដាក់គន្លឹះស្រយ៉ូវដើម្បីទប់គ្រប់សន្លឹកបង្អួចពេលបើក។

**២៩-គ្រឿងបង្គុំទ្វារ និង គ្រឿងបង្គុំបង្អួច**

គ្រឿងបង្គុំទ្វាររួមមាន: គ្រោងទ្វារ សន្លឹកទ្វារ ត្រចៀកទ្វារ ដៃទ្វារ សោ និងរនុកទ្វារ សម្រាប់ទប់ទ្វារ នៅពេលបើក និង បិទ។ល។ គ្រឿងបង្គុំបង្អួចរួមមាន: គ្រោងបង្អួច សន្លឹកបង្អួច ចំរឹងដែក ស្រយ៉ូវ គន្លឹះទប់ បង្អួច ស្លាបព្រិល ត្រចៀកបង្អួច រនុកបង្អួចខាងលើ និង ខាងក្រោម។ល។

**៣០-គ្រោងទ្វារ និង គ្រោងបង្អួច**(**ឈើ**)

គ្រោងទ្វារ និង គ្រោងបង្អួចទាំងអស់ត្រូវធ្វើអំពីឈើដែលមានគុណភាពលេខ១ គឺ ដូងថែម ធ្នឹក គគីរ ធ្នង់ ស្រឡៅ និង សុក្រំ។ ឈើដែលត្រូវយកមកធ្វើគ្រោងទ្វារ និង គ្រោងបង្អួច ត្រូវហាលឲ្យស្ងួតរយៈពេល ៤៥ថ្ងៃ មុនពេលយកមកប្រើ។ មុខតំណតាមជ្រុងនីមួយៗ ត្រូវជ្រៀកចំពាក់កណ្តាល ហើយវាយដែកគោលទំហំគ្រោងទ្វារ និង បង្អួចត្រូវធ្វើទៅតាមប្លង់លម្អិត

ដែលមានក្នុងកិច្ចសន្យា។ នៅតាមបង្អួចនីមួយៗ ត្រូវដាក់ចំរឹង ដែកបញ្ឈរ។ ចំរឹងដែកត្រូវធ្វើអំពីដែកមូលដែលមានទំហំ ១៤មម ហើយលាបថ្នាំ ការពារច្រែះស៊ី ឈ្មោះ RED OXIDE ពីរស្រទាប់រួច ទើបលាបថ្នាំប្រេងសម្រាប់ដែកពណ៌ ប្រផេះពីរស្រទាប់ទៀត។

## ៣១-ត្រចៀកបង្អួច និងត្រចៀកទ្វារ

បន្ទះទ្វារ ត្រូវដាក់ត្រចៀក និង បង្អួចទាំងអស់ត្រូវដាក់ត្រចៀក ៣កន្លែង ដូចដែលបានបង្ហាញនៅក្នុងគំនូសប្លង់ដែលផ្តល់ដោយនាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា។ ត្រចៀកទ្វារ និងបង្អួចមានកម្រាស់៣មមត្រូវលាក់ចូលក្នុងឈើ ដើម្បីដាក់ឲ្យស្មើទៅនឹងផ្ទៃសាច់ឈើ។ ត្រចៀកទ្វារ និង ត្រចៀកបង្អួច ផលិតឡើងពី បន្ទះដែកដែលមានគុណភាពខ្ពស់ ហើយត្រូវភ្ជាប់វាទៅនឹងសាច់ឈើដោយប្រើវីសសម្រាប់ឈើ ដែលមានប្រវែងអប្បបរិមា ៣០មម។ ត្រចៀកទ្វារ បង្អួច និង សន្លឹកទ្វារបង្អួច ត្រូវតម្លើងឲ្យបាន ឈរត្រង់ល្អ ក្នុងពេលបិទ ឬ បើក។

## ៣២-រនុកទ្វារ និង រនុកបង្អួច

រនុកបង្អួចទាំងអស់ត្រូវដាក់ខាងលើនិងខាងក្រោមសន្លឹកបង្អួច។ រនុកទ្វារទាំងអស់ត្រូវដាក់ខាងលើ និងខាងក្រោមនៃបន្ទះទ្វារខាងឆ្វេង។ រនុកទ្វារបង្អួចខាងលើត្រូវមានប្រវែង ៤០០មម ហើយខាងក្រោម ត្រូវមានប្រវែង១៤០មម ។ រនុកទាំងអស់ត្រូវក្រូម៉េអាណូដសង្កសី។ ត្រូវប្រើវីសសម្រាប់ឈើប្រវែង ៣០មម ដើម្បីចាប់រនុកភ្ជាប់នឹងគ្រោងឈើ។ រន្ធសឺករនុកត្រូវ ខួងចូលទៅក្នុងគ្រោងឈើ និង កម្រាលបេតុងឲ្យបានជម្រៅ ២០មម។

## ៣៣-ការតម្លើងគ្រឿងទ្វារ និង បង្អួច

គ្រឿងដូចជា ដៃកាន់ គន្លឹះ ទ្វារ បង្អួច។ល។ ត្រូវតំឡើងសាកដើម្បីដាក់ឲ្យត្រូវទៅតាម ទីកន្លែងវាហើយបន្ទាប់មកដោះចេញវិញមុនពេលធ្វើការលាបថ្នាំទៅលើផ្ទាំងបង្អួច និង ទ្វារ។ សកម្មភាពនេះគឺដើម្បីទប់ស្កាត់នូវការលាបថ្នាំជ្រុលទៅលើគ្រឿងទ្វារបង្អួច ឬ ដើម្បីទប់ស្កាត់ នូវភាពប្រឡាក់ទៅលើផ្ទៃគ្រឿងដែលគេតំឡើងនោះ។

## ៣៤-ការលាបថ្នាំទ្វារ និងបង្អួច

ផ្ទៃទាំងអស់ដែលត្រូវលាបថ្នាំ ត្រូវកោសខាត់ឲ្យស្មើស្អាត គ្មាននៅសល់កំទេចកំទីអ្វីឡើយ។ ត្រូវលាបថ្នាំការពារឈើ (Primer) មួយស្រទាប់ដំបូងនៅលើផ្ទៃទ្វារ និង បង្អួចទាំងអស់ឲ្យបានសព្វ មុននឹងលាបថ្នាំ (Enamel Paint) ប្រផេះចំនួនពីរស្រទាប់ថែមពីលើទៀត។ ស្រទាប់ថ្នាំដែលអាចទទួលយកបានលុះត្រាតែ រលោង និងជាប់ល្អ។

### ៣៥-ការលាបថ្នាំចំរឹងបន្ទួច

ត្រូវកោសខាត់សម្អាតច្រែះសរសៃដែកឲ្យបានស្អាតល្អមុនពេលលាបថ្នាំ។ លាបថ្នាំច្រែះ (RED OXIDE) មួយស្រទាប់ដំបូងនៅលើផ្ទៃដែកទាំងអស់ឲ្យបានសព្វ មុននឹងលាបថ្នាំប្រេងពណ៌ប្រផេះចំនួនពីរស្រទាប់ថែមពីលើទៀត។ ស្រទាប់ថ្នាំប្រេងដែលអាចទទួលយកបាន លុះត្រាតែ រលោង និងជាប់ល្អ។

### ៣៦-ការលាបកំបោរ

ផ្ទៃជញ្ជាំងទាំងអស់ដែលត្រូវលាបកំបោរ ត្រូវតែកោសខាត់ឲ្យស្មើស្អាត គ្មាននៅសល់កំទេចកំទីអ្វីឡើយ។ ផ្ទៃទាំងអស់ត្រូវស្អាត និង ស្ងួតជានិច្ច មុនពេលចាប់ផ្តើមលាបកំបោរ។ ល្បាយត្រូវលាយការស្បែកក្របីនិងទឹកកំបោរស។ ថ្មកំបោរនិងទឹកក្រោយពីត្រាំរួចហើយ ត្រូវទុកចោលឲ្យបានរយៈពេល ៨ម៉ោង ដើម្បីធានានូវគុណភាពកំបោរ និង ដីលែង។ សមាមាត្រល្បាយគឺ កំបោរលេខមួយ ១០០kg និងការស្បែកក្របី ៥kg។ ទឹកកំបោរត្រូវច្រោះយកកំទេចកំទីឲ្យអស់ មុនពេលប្រើប្រាស់។ ផ្ទៃជញ្ជាំងទាំងអស់ត្រូវលាបកំបោរឲ្យបានបីស្រទាប់ ហើយចន្លោះពេលនៃ ការលាបកំបោរមួយស្រទាប់ៗ ទុករយៈពេល ២៤ម៉ោង យ៉ាងតិច។

### ៣៧-បង្គន់អនាម័យ

បង្គន់អនាម័យចាំបាច់សាងសង់ដោយប្រើប្រាស់ប្លង់លំអិតបច្ចេកទស និងលក្ខណៈបច្ចេកទេសលើការងារផ្សេងៗដូចក្នុងឯកសារកិច្ចសន្យា ។

## ខ-សេចក្តីណែនាំលំអិតលក្ខណៈបច្ចេកទេសនៃសម្ភារៈ

### ១-ល្បាយបេតុង

ការលយាបេតុងទាំងអស់ដែលប្រើប្រាស់នៅក្នុងការសាងសង់នេះ ត្រូវអនុវត្តតាមរូបមន្ត ដែលបានកំណត់។ ការលាយម្តងៗត្រូវប្រើខ្នាតដែលមានរង្វាស់ច្បាស់លាស់។ ហាមមិនឲ្យប្រើការលាយល្បាយដោយដៃឡើយ ។ ល្បាយបេតុងណាដែលមិនបានលាយតាមវិធីត្រឹមត្រូវទេ មិនអាចទទួលយកបានឡើយ។

### ២-វិធីលាយបេតុង

ការលាយបេតុង ត្រូវប្រើម៉ាស៊ីនសម្រាប់លាយបេតុង ដើម្បីឲ្យបេតុងមានល្បាយស្មើសាច់ល្អ។ ការលាយបេតុងមិនអាចទទួលយកបាន ប្រសិនបើការលាយបេតុងនោះមិនប្រើម៉ាស៊ីនលាយបេតុង។

## ៣-ស៊ីម៉ង់តិ៍

ត្រូវប្រើស៊ីម៉ង់តិ PORTLAND CEMENT M500 ឬមានគុណភាពប្រហាក់ប្រហែល ។ អ្នកម៉ៅការត្រូវបញ្ជាក់ឲ្យបានច្បាស់នៅក្នុងពេលដេញថ្លៃ និងត្រូវមានការអនុញ្ញាតឲ្យប្រើប្រាស់ជាលាយល័ក្សអក្សរពីវិស្វករការដ្ឋាន និងវិស្វករ ក្រសួងជាមុន ។ បញ្ហាការផ្លាស់ប្តូរនេះគឺខាងភាគីអ្នកសាងសង់ទទួលខុសត្រូវ ក្នុងការផ្តល់នូវឯកសារបច្ចេកទេសច្បាស់លាស់ ពីការប្រើប្រាស់ប្រភេទស៊ីម៉ង់តិផ្សេងទាំងនេះមកម្ចាស់សំណង់ឯកភាពជាមុនសិន ។

ស៊ីម៉ង់ចាំបាច់រក្សានៅកន្លែងស្ងួតការពារនិងរក្សាត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងការពារពីភ្លៀង ដោយមានកំណាល់ផុតពីផ្ទៃដី និង មិនឲ្យប៉ះជញ្ជាំង និងមានចម្ងាយ៥០០មម ពីជញ្ជាំងនោះប្រសិនបើអាធ្វើបាន ។ ការទុកដាក់ស៊ីម៉ង់តិ៍មិនឲ្យខ្ពស់ជាងត្រឹមស្មាមនុស្សឈរឡើយ។

## ៤-ខ្សាច់

ខ្សាច់ដែលប្រើសម្រាប់ផលិតបេតុង គឺខ្សាច់ស្អាត និង មានគុណភាពល្អ។ ការជ្រើយកទំហំនៃខ្សាច់នោះ គឺពី ១មម ទៅ ៥មម ។ ខ្សាច់មិនត្រូវឲ្យមានបំណែកដីឥដ្ឋ ឬកំទេចកំទីអ្វី ឡើយ។

## ៥-ថ្ម

ថ្មដែលប្រើប្រាស់សម្រាប់ផលិតបេតុង គឺ ជាថ្មស្អាត រឹង និង មាំ ។ ថ្មត្រូវមានសភាពដូចគ្នា និងមានទំហំ ១០ x២០មម ដូចគ្នា មានរាងត្រីកោណ និងមិនត្រូវមានធូលី ឬកំទេចម៉ដ្ឋ បំណែកតូចៗនៃថ្ម នៅក្នុងថ្មឡើយ។

## ៦-ដែកសសៃ

ដែកសរសៃទាំងអស់ និង លួសចំណងដែលប្រើក្នុងការងារបេតុងអាម៉េត្រូវមានខ្នាត ពេញលេញ និងមិនច្រេះ។សរសៃដែកដែលមានកំរិតលំអៀងមិនពេញលេញមិនអនុញ្ញាត។ចំពោះសរសៃដែកមានអង្កត់ផ្ចិត លើសពី ១០មមចាំបាច់ជាដែកថ្នាំងអំពៅ។សរសៃដែកត្រូវតែរៀបចំមានលក្ខណៈបង្គុំមាំមិនទ្រេតទ្រោតខុសទីតាំងនៅពេលចាក់បេតុង និងការប្រើម៉ាស៊ីនរំញ័របង្ហាប់បេតុង។សរសៃដែករលោងចាំបាច់មានរ៉េស៊ីស្តង់ ២៥០ N/mm2 និងដែកថ្នាំងអំពៅ ចាំបាច់ត្រូវមានរ៉េស៊ីស្តង់ ៣៩០ N/mm2 ឬ លើសពីនេះ។សរសៃដែកមិនត្រូវមានទំងន់តិចជាងស្តង់ដាកំណត់ដូចខាងក្រោម:

| Diameter | Kg/m |
|---|---|
| Ø6mm | 0.222 Kg/m |
| Ø10mm | 0.617 Kg/m |
| Ø12mm | 0.888 Kg/m |
| Ø14mm | 1.208 Kg/m |

**៧-ទឹក**

ភាគីទទួលការងារម៉ៅការ ត្រូវធានាឲ្យបានត្រឹមត្រូវនូវបរិមាណទឹកដែលត្រូវប្រើ ក្នុងល្បាយបេតុង។ ការដែលប្រើទឹកច្រើនវាបណ្ដាលឲ្យបេតុងខ្សោយ។ ទឹកដែលប្រើសម្រាប់ លាយបេតុងគឺជាទឹកស្អាតល្អ ។ ភាគីទទួលការងារម៉ៅការ មិនត្រូវយកទឹកស្រះល្អក់មកប្រើទេ។ ទឹកល្អក់ដែលមានកករត្រូវរក្សាទុកក្នុងរយៈពេលមួយ ដើម្បីធ្វើឲ្យរងមុននឹងយកមកប្រើ។ សម្រាប់ការលាយបេតុងត្រូវបូមចេញពីផ្នែកខាងលើនៃ អាងស្តុកទឹក។

**៨-ការចាប់បេតុង**

ការចាក់បេតុងចូលទៅក្នុងពុម្ពបានលុះត្រាតែក្តារពុម្ពនោះមានទំហំត្រឹមត្រូវរឹងមាំហើយគ្មានសល់កំទេចកំទីអ្វីឡើយ។ ការជញ្ជូនបេតុងនិងការចាក់បេតុងទៅក្នុងក្តារពុម្ព មិនត្រូវឲ្យកំពប់ខ្ចាយ ឬក៏ហូរចេញពីក្តារពុម្ពឡើយ។ ការចាក់បេតុងត្រូវ ធ្វើបន្តរហូត ដល់ចប់នៃ គ្រឿង បង្គុំនីមួយៗ។ **ឧទាហរណ៍៖** បើចាក់បេតុងចូលទៅក្នុងសសរណាមួយ ត្រូវបន្តការចាក់បេតុងនោះឲ្យ បាន រួចរាល់១០០% មិនត្រូវឈប់កណ្តាលទីឡើយ។ មិនត្រូវបញ្ឈប់ការចាក់បេតុងរបស់ខ្លួនក្នុង ពេលបាយថ្ងៃត្រង់ ឬ ពេលសម្រាកឡើយ។ ត្រូវមានគម្រោងអនុវត្តន៍ឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការផ្អាកសកម្មភាពចាក់បេតុងក្នុងពេលណាមួយដែលមិនទាន់ចប់។ ត្រូវចាក់បេតុងដោយប្រុងប្រយ័ត្នបំផុតទៅក្នុងគ្រប់ផ្នែកទាំងអស់ នៃ ពុម្ព ហើយគេត្រូវគោះផ្នែកខាងក្រោម។ មិនត្រូវឲ្យមានពពុះខ្យល់សល់ចន្លោះប្រហោង ហើយត្រូវទប់ដែកសសៃមិនឲ្យ ងាករេខុសទិសដៅ។

**៩-ការប្រើម៉ាស៊ីនរំញ័រក្នុងការងារចាក់បេតុង**(Vibrator)

ត្រូវបង្ហាប់បេតុងដោយប្រើម៉ាស៊ីនរំញ័រ។ ការរំញ័របេតុង គឺ ធានាឲ្យល្បាយបេតុងដែលគេ ចាក់ចូលបានស្មើសាច់និងហាប់ណែននៅគ្រប់ទ្រង់ទ្រាយទាំងអស់ និង ស្រោបជុំវិញដែកសរសៃ ឲ្យបានពេញលេញ។ភាគីទទួលការងារម៉ៅការត្រូវធានាឲ្យបានថាពុម្ពត្រូវតែរឹងមាំ ដែលអាចធន់នឹងកំលាំងម៉ាស៊ីនរំញ័របាន។ការងារបេតុងដែលមិនបានប្រើម៉ាស៊ីនរំញ័រក្រោយមកឃើញថាមានប្រហោង និង មិនហាប់ណែន មិនអាចទទួលយកបានឡើយ ហើយត្រូវធ្វើសារជាថ្មីឡើងវិញ។

**១០-ការថែរក្សាបេតុង**

បន្ទាប់ពីបេតុងបានចាប់ផ្តើមរឹងមាំ បេតុងនេះត្រូវគ្របដោយប្រដាប់រក្សាសំណើមចំនួន ៣ថ្ងៃ។ ការងារនេះ គឺ ដើម្បីកាត់បន្ថយនូវការប្រេះដែលបណ្តាលពីភាពឆាប់ស្ងួតពេក។ ក្រណាត់ដែលល្អសម្រាប់ ក្រាលគ្របពីលើ គឺ បាវក្រចៅ។ ត្រូវរក្សាសំណើម លើផ្ទៃបេតុងរយៈពេល ៣ថ្ងៃយ៉ាងតិច។

## ១១-គោលការណ៍នៃការលាយបេតុង

កំលាំងបេតុងសម្រាប់គ្រឹះ ធ្នឹមទាំងអស់ កម្រាល សសរ និង ឡាំងតូ គឺ 200Kg/cm²។ អ្នកមៅការត្រូវលាយតាមរូបមន្តសម្រាប់លាយល្បាយបេតុងមានដូចខាងក្រោម។ រាល់ការលាយបេតុងត្រូវសរសេរជាលាយល័ក្សអក្សរសុំការអនុញ្ញាត្តិពីវិស្វករការដ្ឋាន និងវិស្វករក្រសួង។ ការលាយបេតុងក្នុងមួយម៉េត្រគូប (១ម²) ត្រូវលាយដូចខាងក្រោមះ

១-ស៊ីម៉ង់ត៍ ៣៥០ គីឡូក្រាម

២-ខ្សាច់គ្រើមស្អាត ០.៥០ ម³

៣-ថ្មទំហំ ១០x២០មម ០.៩០ ម³

៤-ទឹកស្អាត ២២០ លីត្រ

## ១២-បាយអរ

ការលាយបាយអរ គឺ លាយទៅតាមបទដ្ឋានក្នុងការប្រើប្រាស់បាយអរ ស៊ីម៉ង់ត៍ ១ភាគ ខ្សាច់ ៤ភាគ។ មិនត្រូវប្រើខ្សាច់លាយដី ឬ កំទេចកំទីអ្វីឡើយ។ ការប្រើបាយអរមានពីរ ប្រភេទ គឺ បាយអរសម្រាប់ការងាររៀបឥដ្ឋ និង បាយអរសម្រាប់ការងារបូក។ បាយអរត្រូវប្រើប្រាស់ត្រឹម តែ ៣០នាទីប៉ុណ្ណោះ ។

## គ-ការអនុម័តលើការប្រើប្រាស់សម្ភារះសំណង់

សម្ភារះសំណង់មិនកំណត់ម៉ាកទេ។

ជាទូទៅមានការប្រើប្រាស់សម្ភារះសំណង់មួយចំនួនតាមម៉ាកដូចខាងក្រោមះ

1. Cement K-Cement / Camel / Diamond / Siam / Dragon. (Any brand certified as meeting specification of PORTLAND CEMENT M500 will be approved).
2. Steel Vietnam-Italy Steel (V Brand, V SD390) / Vina Kyoei Steel (VKS) / A Brand/ SD390 Brand / HS Brand. (Subject to meeting strength and weight requirements of the specifications).
3. Paint U-90 /Delux /Jotun Paint /Angkor Paint /Nippon Paint /TOA.
4. Ceramic toilet Karat/Tico/Foshan/Champion.
5. Door locks Master/Solex/Solo/Shan-Hvan/Globe/Robson/Daf/Aston/World Ball/ Stanford
6. Roof Tiles CPAC Monier Concrete tiles or any brand of Grade 1 Clay Roof tiles.

## ឃ-អណ្តូងទឹក

## ១-ទីតាំងដែលត្រូវខួង

អ្នកម៉ៅការ ត្រូវខួងអណ្តូង និងបំពាក់ក្បាលស្នប់ ទៅតាមទីតាំងដែលបានឯកភាពដោយម្ចាស់គម្រោង គណ :កម្មការទ្រទ្រង់សាលា ហើយទីតាំងនោះត្រូវស្ថិតនៅក្នុងបរិវេនសាលារៀន។ អណ្តូងមិនត្រូវស្ថិតនៅចំងាយតិចជាង 25mពីបង្គន់ ដោយមិនមានការអនុញ្ញាតិពីអ្នកបច្ចេកទេសនាយកដ្ឋានសំណង់ នៃក្រសួងអប់រំ យុវជន និងកីឡា ឡើយ ។ អ្នកម៉ៅការត្រូវជូនដំណឹងដល់អ្នកបច្ចេកទេសអោយបាន៧ថ្ងៃមុនចាប់ផ្តើមការខួងហើយមិនត្រូវបំពាក់ក្បាលស្នប់ដោយមិនទាន់បានធ្វើពិសោធន៍រកធាទឹកនិងគុណភាពទឹកតាមលក្ខណៈរូប និងលក្ខណៈគីមីនោះឡើយ ។

## ២-គំនូសប្លង់

អ្នកម៉ៅការត្រូវអនុវត្តការងារខួងទៅតាមប្លង់កំណត់ទីតាំងដែលបានព្រមព្រៀងនិងត្រូវប្រើម៉ាស៊ីនខួងតាមការអនុញ្ញាតិរបស់អ្នកបច្ចេកទេសក្រសួងអប់រំ យុវជន និងកីឡា ។

## ៣-អង្កត់ផ្ចិតអណ្តូង

អង្កត់ផ្ចិតរណ្តៅខួងសម្រាប់ស្រទាប់ដី គឺត្រូវយកទំហំ 150mm និងសម្រាប់ស្រទាប់ថ្មត្រូវយកទំហំ 100mm ដើម្បីអោយវាត្រូវនឹងការប្រើប្រាស់បំពង់ជ័រPVC 13.5 ដែលមានអង្កត់ផ្ចិតខាងក្នុង 100mm ។

## ៤-ធាទឹក និងជម្រៅ

អ្នកម៉ៅការត្រូវអនុវត្តការងារខួងអោយដល់ជម្រៅដែលផ្តល់ធាទឹកល្អសម្រាប់ផឹកបាន ក្នុងបរិមាណដែលទាបបំផុត1000លីត្រក្នុងមួយម៉ោង ទើបអាចតម្លើងក្បាលស្នប់បាន។ ធាទឹកមិនអាចតិចជាង 1000លីត្រក្នុងមួយម៉ោងនៅក្នុងរដូវប្រាំង ឬក៏ពេលណាមួយបានទេ ។ គ្មានអណ្តូងណាមួយត្រូវបានបោះបង់ចោលដោយគ្មានការឯកភាពពីវិស្វកររបស់ក្រសួងបានទេ។ ជម្រៅអប្បបរិមារបស់អណ្តូងគឺ 20m ។ អ្នកម៉ៅការត្រូវធ្វើការបូមសាកល្បង ដើម្បីធ្វើអោយប្រាកដអំពីធាទឹក មុននិងតម្លើងក្បាលស្នប់ ។

## ៥-ស្នប់អណ្តូង

ក្បាលស្នប់ ត្រូវប្រើស្នប់ដែលថ្មី ម៉ាក Afridev និងមានភ្ជាប់មកនូវគ្រឿងបន្លាស់ ដូចជារ៉ង កន្លះវ៉ាល់ កូនសោរ និងសម្ភារផ្សេងៗដែលមានភ្ជាប់មកជាមួយពីក្រុមហ៊ុនលក់ ក្បាលស្នប់ ។ ការបំពាក់ស្នប់ អាចធ្វើទៅបានក្រោយពីមានការឯកភាពថាបានជោគជ័យបន្ទាប់ពីខួងរួច គឺមាន

ន័យថា មានធាទឹកដែលអាចបូមបានយ៉ាយតិច 1000 លីត្រក្នុងមួយម៉ោង មាន Turbility ទឹកតិចជាង 5NTU និងមានសមាសភាព Arsenic ក្រោម កម្រិត50PPb ។ អ្នកម៉ៅការត្រូវណែនាំដល់គណៈកម្មាការទ្រទ្រង់សាលា រយៈពេល 2ទៅ3ម៉ោង ពីរបៀបប្រើ ប្រាស់ស្នប់ របៀបថែទាំ និងការផ្លាស់ប្តូរគ្រឿងបន្លាស់ដែលចាំបាច់ ។

## ៦-ការខួងអណ្តូងឡើងវិញ

ប្រសិនបើការខួងលើកទី១មិនបានជោគជ័យ អ្នកម៉ៅការត្រូវធ្វើការខួងមួយកន្លែងទៀតនៅក្នុងទីធ្លាសាលា ដោយមានការយល់ព្រមពីគណៈកម្មការទ្រទ្រង់សាលា និង វិស្វកររបស់ក្រសួង។ ការចំណាយលើការខួងលើកទី២នេះគឺជាបន្ទុករបស់អ្នកម៉ៅការ ដោយមិនមានបន្ថែមប្រាក់លើកិច្ចសន្យាឡើយ។

## ៧-ជម្រៅរបស់បំពង់ចម្រោះ

អ្នកម៉ៅការត្រូវដាក់បំពង់ និងបំពង់ចម្រោះ (Filter)អោយដល់ជម្រៅដែលទទួលបានលទ្ធផលទឹក និងគុណភាពទឹកល្អ ដែលជម្រៅនេះវាប្រែប្រួលតាមលក្ខណៈស្រទាប់ដី និងត្រូវបានឯកភាពដោយវិស្វករ។

## ៨-បំពង់ជ័រ និងបំពង់ចម្រោះ

អ្នកម៉ៅការត្រូវដាក់បំពង់ជ័រដែលមានគុណភាពតាមស្តង់ដាដែលទទួលយកដោយអ្នកបច្ចេកទេសគម្រោង(ក្រសួងអយក)។អ្នកម៉ៅការមិនត្រូវប្រើប្រាស់បំពង់ចម្រោះដែលអារដោយដៃឡើយ ។ អង្កត់ផ្ចិតរបស់បំពង់ចម្រោះមានទំហំដូចគ្នា និងបំពង់អណ្តូងស្នប់ដែរ ។ បាតបំពង់របស់អណ្តូងត្រូវបិតឲ្យបានជិតត្រឹមត្រូវ ។ បំពង់អណ្តូងមិនត្រូវប្រើប្រាស់បំពង់ដែលមានអង្កត់ផ្ចិតតូចជាង 100mm ឡើយ ។

## ៩- ឯកសារ Log Sheet

អ្នកម៉ៅការត្រូវធ្វើរបាយការណ៍អំពីការខួង និងបំពេញ Log Sheet របស់អណ្តូងនីមួយៗ ដាក់ជូនម្ចាស់គម្រោង (ក្រសួង អយក) ។

## ១០- ជើងទ្រស្នប់

អ្នកម៉ៅការត្រូវសង់ជើងទ្រស្នប់ពីបេតុងអាម៉េ ទំហំ 50x50x50cm ដូចបង្ហាញនៅ ក្នុងប្លង់បច្ចេកទេស ដើម្បីឲ្យស្នប់មានភាពរឹងមាំ និងមានលំនឹង ។

## ១១- ការឆ្លងឆ្លាក់តេរីចូលអណ្តូងពេលកំពុងសាងសង់

អ្នកម៉ៅការត្រូវយកចិត្តទុកដាក់ការពារកុំឲ្យមានបំពុលដោយជាតិគីមីឬឆ្លងបាក់តេរីពេលសាងសង់អណ្តូង ។

## ១២- ខឿនអណ្តូង

អ្នកម៉ៅការត្រូវសង់ខឿនអណ្តូងស្នប់ពីបេតុង រែងសសៃដែកតាមប្លង់លំអិតបច្ចេកទេស ដែលផ្តល់ដោយនាយកដ្ឋានសំណង់ នៃក្រសួងអប់រំ យុវជន និងកីឡា ។

## ១៣- ការចេញចូលការដ្ឋាន

ម្ចាស់គម្រោង (វិស្វករ) មានសិទ្ធក្នុងការចូលទៅពិនិត្យការងារខួង និងតាមដានការរីកចំរើនក្នុងការអនុវត្តការងារសាងសង់ របស់អ្នកម៉ៅការ ។ មិនមានការងារណាមួយ ដែលធ្វើឲ្យលាក់កំបាំង ឬដោយគ្មានការឯកភាព ពីម្ចាស់គម្រោង(វិស្វករ)ឡើយ ។ ការកែប្រែលើប្លង់ ប្រសិនបើមានការចាំបាច់ត្រូវពិគ្រោះ និងមានការឯកភាពដោយម្ចាស់គម្រោង(វិស្វករ)សិន មុននឹងធ្វើការអនុវត្ត ។ អ្នកម៉ៅការមិនអាចទាមទារប្រាក់ពីការងារណាដែលធ្វើការផ្លាស់ប្តូរ ឬការងារបន្ថែមណាដែលពុំមានការអនុញ្ញាតពីម្ចាស់គម្រោងឡើយ ។

## ១៤- ការទុកដាក់សម្ភារសំណង់

អ្នកម៉ៅការត្រូវទទួលខុសត្រូវសន្តិសុខសុវត្ថិភាព និងការរក្សាទុកសម្ភារសំណង់ និងឧបករណ៍សំណង់ក្នុងកំឡុងពេលសាងសង់តាមកិច្ចសន្យា ។ អ្នកម៉ៅការត្រូវការពារកុំឲ្យកូនសិស្ស ក្មេងៗ ឬអ្នកដ៏ទៃចូលដល់ទីតាំងដែលកំពុងខួងអណ្តូង និងត្រូវការពារបំពង់អណ្តូងដែលចំហរពេលខួងរួច កុំឲ្យក្មេងៗប៉ះពាល់ ឬធ្វើឲ្យមានការឆ្លងមេរោគ បាក់តេរីចូលក្នុងអណ្តូង ។

## ១៥- មិនមានការទូទាត់ប្រាក់សំរាប់អណ្តូងស្ងួត

បើសិនជាអណ្តូងមិនមានទឹក ឬផ្តល់ទឹកមិនបានដល់កម្រិតអប្បបរិមា 1000លីត្រ ក្នុង 1ម៉ោង បន្ទាប់ពីការខួងដល់ជំរៅសមរម្យ ធៀបនឹងជម្រៅអប្បបរិមា អណ្តូង នោះចាត់ទុកថាជាអណ្តូងស្ងួត គឺត្រូវតែបោះបង់ចោល ។អណ្តូងដែលបោះបង់ចោលត្រូវបិតឲ្យជិតដោយប្រើបេតុង។ អ្នកម៉ៅការនឹងមិនត្រូវបានបើកប្រាក់ជូនទេសំរាប់អណ្តូងស្ងួត ។

## ១៦- ការធ្វើពិសោធន៍លក្ខណៈរូប និងលក្ខណៈគីមី

ប្រសិនបើចាំបាច់ម្ចាស់គម្រោងនឹងធ្វើពិសោធន៍លក្ខណៈរូប និងលក្ខណៈគីមី របស់ទឹករួមទាំង Turbility និងសមាសភាព Arsenic ។ ក្នុងករណីទឹកអណ្តូងមាន Turbility លើសពី 5NTU

អណ្តូងនោះមិនអាចទទួលយកបានទេ ហើយអ្នកម៉ៅការត្រូវធ្វើឡើងវិញ រហូតដល់កំរិត Turbility ទាបជាង 5NTU ។ មិនមានការបើកប្រាក់ជូនទេករណីអណ្តូងមានកម្រិត Turbility លើសពី 5NTU ។ បើអណ្តូងមានកំរិត Arsenic លើសពី 0.05mg/l នោះអណ្តូងក៏ត្រូវតែបោះបង់ចោលដែរ។ ករណីអណ្តូងមានទឹកតែមានជាតិ Arsenic ខ្ពស់ អ្នកម៉ៅការមានសិទ្ធស្នើសុំបើកប្រាក់សម្រាប់តែតម្លៃការងារខួងអណ្តូងប៉ុណ្ណោះគឺមិនមានការបើកប្រាក់សម្រាប់ក្បាល ស្នប់និងខឿនអណ្តូងឡើយ។

## ១៧- ការសម្លាប់មេរោគសំរាប់អណ្តូង

អ្នកម៉ៅការត្រូវសម្លាប់មេរោគដោយប្រើល្បាយ សូលុយស្យុង Hypochlorite យ៉ាងតិច 24ម៉ោង រួចចាប់ផ្តើមបូម ឬសប់ឲ្យស្អាតអស់សារធាតុ Chlorine ។

## ១៨- ការលុបចេញការងារពីកម្មវិធីការងារ

ម្ចាស់គម្រោងអាចលុបចោលនូវការងារទាំងឡាយដែលមាននៅក្នុងកិច្ចសន្យាគ្រប់ពេលបាន គឺនៅមុនពេលដែលអ្នកម៉ៅការចាប់ផ្តើមធ្វើការងារដែលត្រូវលុបចេញនោះ ប្រសិនបើម្ចាស់គម្រោងសម្រេចថាត្រូវលុបចេញ ដោយមូលហេតុណាមួយក៏ដោយ ។ អ្នកម៉ៅការមិនត្រូវបានទូទាត់ប្រាក់ជូនសំរាប់ការងារដែលត្រូវបានលុបចេញពីកម្មវិធីការងារឡើយ ហើយម្ចាស់គម្រោងមានការទទួលខុសត្រូវជូនដំណឹងដល់អ្នកម៉ៅការជាលាយល័ក្ខអក្សរជាមុនអំពីការ លុបចេញនោះ ។

## ១៩- ការបញ្ចប់ការសាងសង់

ការងារត្រូវបានចាត់ទុកថាបានបញ្ចប់ គឺ នៅពេលដែលការងារអណ្តូងទឹកត្រូវបានបញ្ចប់និងអាចទទួលយកបាន ដូចមាត្រានានាទៀត ក្នុងកិច្ចសន្យា ហើយអណ្តូងអាចផ្តល់ទឹកបានយ៉ាងតិច 1000លីត្រ ក្នុង មួយម៉ោង បានបំពាក់ស្នប់ថ្មីម៉ាក Afridev នឹងធ្វើខឿនអណ្តូងធ្វើពីបេតុងអាម៉េត្រឹមត្រូវតាមប្លង់បច្ចេកទេស និងបានផ្តល់ការពន្យល់ណែនាំពីការជួសជុល ប្តូរគ្រឿងបន្លាស់ ហើយការងារទាំងអស់ត្រូវបានធ្វើពិសោធន៍សាកល្បង និងមានការពេញចិត្ត ដូច មានចែងក្នុងកិច្ចសន្យា ។ ម្ចាស់គម្រោង និងចេញវិញ្ញាប័នប័ត្របញ្ចប់ការងារសាងសង់ដល់អ្នកម៉ៅការដោយបញ្ជាក់ពីកាលបរិច្ឆេតនៃការបញ្ចប់ការងារសាងសង់ ហើយដើម្បីចាប់ផ្តើមរាប់រយៈពេលថែរក្សា សុពលភាពសំរាប់រយៈពេលដប់ពីរ( ១២)ខែ ។

### ២០- ការថែទាំ និងរយៈពេលសុពលភាព

អ្នកម៉ៅការត្រូវថែទាំអណ្តូងដែលបានខួងជោគជ័យ និងខឿនរបស់វាសំរាប់រយៈពេល ១២ខែ បន្ទាប់ពីបញ្ជាក់ថាបានបញ្ចប់ការងាររួចរាល់តាមកិច្ចសន្យា។ ក្នុងកំឡុងពេលថែទាំ និងរយៈពេលសុពលភាព អ្នកម៉ៅការត្រូវទទួលខុសត្រូវសម្រាប់ការជួសជុល និងការថែទាំ ដែលចាំបាច់ដើម្បីឲ្យអណ្តូងដំណើរការបានល្អជានិច្ច ករណីបើអណ្តូងលែងផ្តល់ទឹកបាន 1000លីត្រ ក្នុងមួយម៉ោង នោះអ្នកម៉ៅការត្រូវធ្វើអណ្តូងឡើងវិញ ។ អ្នកម៉ៅការត្រូវទទួលខុសត្រូវថែទាំបេតុងខឿនក្នុងអំឡុងពេលសុពលភាពផងដែរ រាល់ការខូចខាត ប្រេះ ឬ ស្រុតនៃខឿនគឺត្រូវជួសជុលឡើងវិញដោយប្រើថវិការបស់អ្នកម៉ៅការ ។

## IV-ការគ្រប់គ្រងការដ្ឋាន និងការពិនិត្យតាមដាន

ព្រះរាជាណាចក្រកម្ពុជាពុំទាន់មានស្តង់ដាជាតិ ឬកំកំណត់យកតាមស្តង់ដាអន្តរជាតិណានៅឡើយលើសម្ភារសំណង់ និងការងារធ្វើពិសោធន៍លើសម្ភារសំណង់ ។ ដើម្បី ធានាបាន នូវ ជាសុខភាព សុវត្ថិភាព និងគូសប្លង់ប្រកបដោយបរិស្ថានល្អ គំនូសប្លង់សាលារៀន និងល័ក្ខខ័ណ្ឌចាំបាច់នៃហេដ្ឋារចនាសម្ព័ននានាដែលមានក្នុងគោលការណ៍ណែនាំនេះ ត្រូវតែអនុវត្ត ដោយម៉ត់ចត់ ដោយក្រុមហ៊ុនសាងសង់ និងត្រួតពិនិត្យជាប្រព័ន្ធ ព្រមទាំងតាមដាន និងវាយតម្លៃដោយនាយកដ្ឋានជំនាញ ការិយាល័យជំនាញ និងដោយមន្ត្រីជំនាញម្នាក់ៗរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។ ខាងក្រោមនេះ ជាការសង្ខេបពីតួនាទីនិងការទទួលខុសត្រូវរបស់ការិយាល័យជំនាញ នាយកដ្ឋានជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្នាក់ជាតិ និងក្រោមជាតិរបស់អ្នកម៉ៅការសាងសង់ និង គណៈកម្មការទ្រទ្រង់សាលា ។

### ៤-១ នាយកដ្ឋានសំណង់

នាយកដ្ឋានសំណង់ជាអ្នកទទួលខុសត្រូវរាល់ហេដ្ឋារចនាសម្ព័ន្ធ របស់ក្រសួងអប់រំ យុវជន និងកីឡា ហើយមានតួនាទីអនុវត្តនិងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពសេចក្តីណែនាំនេះ។ នាយកដ្ឋានសំណង់ តាមរយៈវិស្វករ (Central Engineer) ដែលនឹងធ្វើការត្រួតពិនិត្យជាប្រចាំ តាមការដ្ឋានសាងសង់។ វិស្វករត្រួតពិនិត្យការដ្ឋាន ដែលមកពីនាយកដ្ឋាន។ វិស្វករនាយកដ្ឋានមានតួនាទីត្រួតពិនិត្យទៅលើវិស្វករប្រចាំការដ្ឋាន ដើម្បីធានាថា វិស្វករការដ្ឋានទាំងនោះបាន ត្រួតពិនិត្យលើគុណភាពសំណង់ទាន់ពេលវេលា ។

នាយកដ្ឋានសំណង់ ក៏មានការ ទទួលខុសត្រូវលើការងារបញ្ចប់តាមជំហាននិមួយៗនៃការងារសាងសង់ហើយពិនិត្យវាយតម្លៃលើការងារទូទាត់តាមការងាររីកចំរើនរបស់ក្រុមហ៊ុនសាងសង់។ ការទទួលខុសត្រូវដំបូងនៅក្នុងការកំណត់បញ្ចប់នៃការងារសាងសង់នៅពេលដែលក្រុមហ៊ុនសាងសង់បានដាក់សំណើសុំប្រគល់អគារមក ក្រសួង /នាយកដ្ឋានសំណង់។

ក្រៅពីការអនុវត្តនិងគ្រប់គ្រងកិច្ចសន្យា នាយកដ្ឋានមានបន្ទុកទទួលខុសត្រូវលើការងាររៀបចំនូវបណ្ណសារស្ថាបត្យកម្មនិងបណ្ណលិខិតអមបច្ចេកទេសគ្រប់ប្រភេទនៃហេដ្ឋារចនាសម្ព័ន្ធបរិមាណការងារសាងសង់ បញ្ជីប៉ាន់ស្មាននិងទទួលបន្ទុកក្នុងការងារកំណត់ទីតាំងណាដែលចាំបាច់ត្រូវធ្វើការពិសោធន៍ស្រទាប់ដីដើម្បីទ្រទ្រង់គ្រឹះនៃអគារ។

នាយកដ្ឋានទទួលខុសត្រូវផងដែរលើការងារផ្ទៀងផ្ទាត់បញ្ជីប៉ាន់ស្មានដែលក្រុមហ៊ុនសាងសង់បានដាក់ក្នុងឯកសារដេញថ្លៃនិងរៀបចំធ្វើការវាយតម្លៃនិងប្រៀបធៀបឯកសារដេញថ្លៃដោយធ្វើតាមឯកសារស្តង់ដារលទ្ធកម្មនៃព្រះរាជាណាចក្រកម្ពុជា (SOP)។

នាយកដ្ឋានក៏នឹងត្រូវចូលរួមក្នុងការងារនានាពាក់ព័ន្ធនឹងការសាងសង់ រួមមានក្នុងគណ កម្មាការលទ្ធកម្ម ការបើកកញ្ចប់ដេញថ្លៃ និងការប្រជុំតាមការរីកចម្រើននានា។

## ៤-២ ការចុះត្រួតពិនិត្យតាមដានរបស់វិស្វករក្រសួងអប់រំ យុវជន និងកីឡា

វិស្វករក្រសួងនឹងចុះពិនិត្យតាមដានការងារសាងសង់តាមការដ្ឋាននៅក្នុងជំហានសំខាន់ៗនៃការងារសាងសង់។ វិស្វករក្រសួងនឹងចុះពិនិត្យវាយតម្លៃលើការងារសាងសង់បញ្ចប់នៅពេលមានសំណើពីការិយាល័យគ្រប់គ្រងសំណង់មកដល់ក្រសួង/នាយកដ្ឋានសំណង់ ដោយពិនិត្យលើចំនុចខ្វះខាត និងកំណត់វិធីសាស្ត្រកែលំអចំនុចខ្វះខាតទាំងនោះ។ ជាមួយគ្នានេះ វិញ្ញាបនបត្រនៃការងារបញ្ចប់នៃសំណង់នឹងរៀបចំនៅពេលធ្វើការប្រគល់ទទួល។

វិស្វករក្រសួងត្រូវមានភារកិច្ចចុះពិនិត្យតាមដានវាយតម្លៃលើគុណភាពទាំងពីរ ការងារសំណង់ និងការងារទទួលខុសត្រូវរបស់វិស្វករប្រចាំការដ្ឋាន ដោយធ្វើការកែលម្អតួនាទីនិងភារកិច្ចទទួលខុសត្រូវរបស់វិស្វករប្រចាំការដ្ឋានដូចមាននៅក្នុងកិច្ចព្រមព្រៀងកិច្ចសន្យា។

នៅពេលការចុះពិនិត្យការដ្ឋាន វិស្វករក្រសួង/នាយកដ្ឋានចាំបាច់ត្រូវបំពេញឯកសារដែលមាននៅក្នុង(ឧបសម្ព័ន្ធ)។ការបំពេញទាំងឯកសារទាំងអស់នេះ ចាំបាច់ភ្ជាប់នឹងទាំងឯកសាររូបថត។ រាល់ការងារចុះពិនិត្យការដ្ឋានចាំបាច់ត្រូវថតចំលងនូវបទបញ្ជាដែលវិស្វករបានដាក់ចេញតាមការដ្ឋាននិមួយៗភ្ជាប់ជាមួយឯកសាររបាយការណ៍មកក្រសួង/នាយកដ្ឋានសំណង់ដោយភ្ជាប់ជាមួយនូវរបាយការណ៍ អំពីការចុះពិនិត្យការដ្ឋាន ។

វិស្វករត្រូវអនុវត្តការងារគ្រប់ជំហាន ដើម្បីធានាពី គុណភាពសំណង់និងចេញការណែនាំនានាដើម្បីឲ្យការសាងសង់ចប់ទាន់ពេលវេលាដូចក្នុងកិច្ចសន្យា នៅគ្រប់ការពិនិត្យការដ្ឋាននិមួយៗ។

## ៤-៣ ការទទួលខុសត្រូវរបស់វិស្វករប្រចាំការដ្ឋាន

វិស្វករប្រចាំការដ្ឋានត្រូវបំពេញការងារពេញម៉ោងតាមការដ្ឋាន។វិស្វករប្រចាំការដ្ឋានត្រូវទទួលខុសត្រូវលើការងារបច្ចេកទេសតាំងពីចាប់ផ្តើមការងារសាងសង់រហូតដល់ផ្តើមប្រគល់ទទួលសំណង់។ការងារពេញម៉ោងរបស់វិស្វករប្រចាំការដ្ឋានគឺចាប់ពីម៉ោង៨ព្រឹកដល់ម៉ោង១២ថ្ងៃនិងម៉ោង១៣:៣០ល្ងាចដល់ម៉ោង១៧:៣០ល្ងាចរាល់ថ្ងៃធ្វើការ និងក្រៅពីនេះថ្ងៃឈប់សម្រាកប្រសិនបើមានការងារចាំបាច់នៃសំណង់ដូចជាការងារចាក់បេតុងជាដើម។ល។

វិស្វករប្រចាំការដ្ឋានត្រូវពិនិត្យការដ្ឋានគុណភាពសំណង់ធានាឲ្យបានត្រឹមត្រូវតាមគំនូសប្លង់និងលក្ខខណ្ឌបច្ចេកទេស។ ក្នុងករណីមានចំនុចខ្វះខាតវិស្វករប្រចាំការដ្ឋានត្រូវចេញបទបញ្ជាតាមរយៈការសរសេរនៅក្នុងសៀវភៅពិនិត្យការដ្ឋានទៅឲ្យក្រុមហ៊ុន ។ ប្រសិនបើអ្នកម៉ៅការមិនព្រមអនុវត្តន៍តាមវិស្វករប្រចាំការដ្ឋានត្រូវចេញការណែនាំជាលាយល័ក្សអក្សរដើម្បីធានារាល់ការបញ្ជាទាំងអស់ ត្រូវគោរពតាមដោយចុះក្នុងកំណត់ត្រាប្រចាំថ្ងៃ ដើម្បីបានដឹងពីប្រវត្តិនៃការសាងសង់ ត្រូវបានកែលំអ។ វិស្វករការដ្ឋាន ត្រូវបំពេញរបាយការណ៍ប្រចាំថ្ងៃតាមទំរង់ឯកសារដែលមាននៅក្នុង(ឧបសម្ព័ន្ធ)នៅរៀងរាល់ថ្ងៃរួចចងក្រងជាឯកសារ។

នៅចុងសប្តាហ៍ វិស្វករប្រចាំការដ្ឋានចាំបាច់ត្រូវរៀបចំរបាយការណ៍ប្រចាំសប្តាហ៍អំពីការពិនិត្យការដ្ឋាន និងភ្ជាប់ជាមួយរូបថតអំពីស្ថានភាពនៃការសាងសង់ក្នុងសប្តាហ៍កន្លងទៅ ។ របាយការណ៍នេះ ត្រូវរៀបចំដាក់ដោយឡែក ។ របាយការណ៍ប្រចាំសប្តាហ៍ត្រូវរៀបចំរៀងរាល់

ល្ងាចថ្ងៃព្រហស្បត្តិ៍ និងធ្វើការពិភាក្សាជាមួយនាយកសាលា ថ្នាក់ខេត្ត និងវិស្វករក្រសួង និងនាយកដ្ឋានសំណង់។

របាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ចាំបាច់ត្រូវរៀបចំជាប្រចាំ និងមានគម្រោងពេលចុះពិនិត្យតាមដានរបស់វិស្វករក្រសួង បញ្ហាត្រូវតែពិនិត្យដោយផ្ចាហារណាមួយ។

វិស្វករប្រចាំការដ្ឋានត្រូវទទួលខុសត្រូវនឹងអនុវត្តការកិច្ចដែលមានចែងក្នុងកិច្ចការមេត្រៀលគុណភាពសំណង់។រាល់ការងារខុសពីការណែនាំសំណង់ចាំបាច់ត្រូវចេញបទបញ្ជាកែតម្រូវឲ្យបានទាន់ពេលវេលា។នៅពេលចុះហត្ថលេខាមុនចាប់ផ្តើមការងារសាងសង់តាមការដ្ឋាន វិស្វករប្រចាំការដ្ឋានត្រូវពិភាក្សាជាមួយវិស្វកររបស់ក្រុមហ៊ុន ហើយជាពិសេស សព្ទនយ៉ូនរបស់ និងលំអិតបច្ចេកទេសដើម្បីជៀសវៀងរាល់កំហុសឆ្គងបច្ចេកទេសដែលអាចមានឡើង ។ ដូចនេះការងារបណ្តុះបណ្តាលនិងការពន្យល់ណែនាំជាការទទួលខុសត្រូវរបស់វិស្វករប្រចាំការដ្ឋានផងដែរ។

វិស្វករប្រចាំការដ្ឋានត្រូវរៀបចំបញ្ជីហ៊ានគម្រោងការងារីកចំរើនសំណង់ដោយផ្ទៀងផ្ទាត់នឹងសំណើរបស់ក្រុមហ៊ុនសាងសង់និងផែនការងារ ទាំងនេះមកវិស្វករក្រសួងពិនិត្យនិងឲ្យយោបល់ក្នុងការទូទាត់ដោយប្រធាននាយកដ្ឋានសំណង់បញ្ចប់ណាមួយផ្ចាហារណាមួយ។

នៅពេលសំណង់បានបញ្ចប់ វិស្វករប្រចាំការដ្ឋានត្រូវធានាថាគ្មានចំនុចខ្វះខាតនិងការងារសេសសល់ណាឡើយ។ នៅពេលការត្រួតពិនិត្យចុងក្រោយចាំបាច់ត្រូវមានការចូលរួមពីវិស្វករក្រសួង នាយកសាលា គណៈកម្មការទទួលសាលា ។ការងារនេះធ្វើឡើងនៅពេលដែលក្រុមហ៊ុនបានដាក់សំណើបរិគ្គទទួល។បន្ទាប់ពីមានការធានាបញ្ចប់សំណង់ជាផ្ចាហារ ក្រុមហ៊ុនសាងសង់ទទួលបានប្រាក់ចំនួន ៩០ភាគរយនៃតម្លៃកិច្ចសន្យាដោយឡែកនៅពេលផ្ទេរបរិគ្គទទួលរួចរាល់ក្រុមហ៊ុនសាងសង់និងទទួលប្រាក់ ៥%នៃតម្លៃកិច្ចសន្យា ហើយ៥% រក្សាទុករយៈពេល ១ឆ្នាំ នៃស្ថិតពលភាពសំណង់ ដោយគិតចាប់ពីបរិគ្គទទួលជាផ្ចាហារ។

## ៤-៤ ការចូលរួមរបស់នាយកសាលា និងគណៈកម្មការទទួលសាលា

នាយកសាលា និងគណៈកម្មការទទួលសាលា មានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់តួនាទីរបស់

ទីតាំង កម្មសិទ្ធិនិង រកទីតាំងសំរាប់សាងសង់។ក្នុងនេះគណៈកម្មការទ្រទ្រង់សាលា អាចមាន ភារកិច្ចដូចខាងក្រោម៖

គណៈកម្មការទ្រទ្រង់សាលា ចូលរួមសហការជួយគ្រប់ពេលដល់សាលា ចុះកិច្ចការរបស់ក្រសួង/នាយកដ្ឋានសំណង់។គណៈកម្មការត្រូវដឹងថា សំណង់អគារសិក្សានៅក្នុងទីតាំងសាលារបស់ខ្លួន ដូចនេះនឹងទទួលបាននូវប្រយោជន៍ពីអគារនេះ ហើយចាំបាច់ត្រូវចូលរួមកាត់បន្ថយរាល់ប៉ះពាល់ផ្សេងៗក្នុងរយៈពេលសាងសង់នេះ ដើម្បីធានាឲ្យបានសំណង់មានគុណភាព និងចប់ទាន់ពេលវេលា។ គណៈកម្មការត្រូវចូលរួមផ្សព្វផ្សាយ ដល់សិស្ស គ្រូ និងសមាជិក ប្រជាជន បើពុំមានការអនុញ្ញាតណាមួយទេ ហាមចូលក្នុងការដ្ឋានសាងសង់ជៀសវាងគ្រោះថ្នាក់ផ្សេងៗ កើតឡើងជាយថាហេតុ។

សម្របសម្រួលក្នុងការតបណ្តាញទឹក និងចរន្តអគ្គិសនី ប្រសិនបើមាន រាល់ការចំណាយលើការត និងលើការប្រើប្រាស់ជាភារកិច្ចរបស់ក្រុមហ៊ុនសាងសង់។

សម្របសម្រួលលើការងារសុវត្ថិភាពការដ្ឋាន ជាពិសេសចំពោះសម្ភារៈសំណង់ ដែលអាចធានា ទុកដាក់បានក្នុងបរិវេណសាលាដែលមានស្រាប់ និងក្នុងសហគមន៍ដោយមិនគិតថ្លៃឈ្នួលឲ្យ សាលា ឬសហគមន៍។

ជួយក្នុងការដោះស្រាយបញ្ហានានា ដែលរារាំងការអនុវត្តន៍កិច្ចសន្យា ដែលជំនួយនេះ ស្ថិតក្នុង ភាពយុត្តិធម៌របស់នាយកសាលា និងសហគមន៍។

## ៤-៥ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត

មន្ទីរអប់រំ យុវជននិងកីឡា ទទួលខុសត្រូវរួម រាល់សកម្មភាព និងការអនុវត្តរបស់ក្រសួងនៅ ក្នុងរាជធានីខេត្តរបស់ខ្លួន។ក្រសួង/នាយកដ្ឋានសំណង់នឹងផ្តល់ព័ត៌មានពីការងារសាងសង់ និង សកម្មភាពនានា នៅមុនពេលចាប់ផ្តើមសាងសង់។ចំពោះរបាយការណ៍នៃការងាររីកចំរើន សំណង់គឺដោយនាយកសាលា ដោយផ្ទាល់មាត់ប្រាប់ទៅលើ យល់ក្នុងអ្នកស។ រាល់ការងារប្រជុំ ពាក់ព័ន្ធនឹងការងារសាងសង់ចាំបាច់ត្រូវមានវត្តមានវិស្វករផងដែរ។

ប្រធានមន្ទីរនឹងចូលរួមជួយដោះស្រាយនៅពេលជួបបញ្ហាធំៗ នៅពេល ឬក្រុមសហគមមិន
ប្រសិនបើបញ្ហានោះស្ថិតក្នុងក្របខ័ណ្ឌឆ្លើយតបចប់នៃការងាររបស់គាត់។ ប្រសិនបើក្នុងពេលពិនិត្យការដ្ឋាន តំណាងរបស់គាត់បានកត់សំគាល់ឃើញមានកំហុសគឺត្រូវធ្វើរបាយការណ៍ទៅវិស្វករការដ្ឋាន និងវិស្វករក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានសំណង់ជាបន្ទាន់ដើម្បីដោះស្រាយទាន់ពេលវេលា ។

## ៤-៦ ក្រុមហ៊ុនសាងសង់

ជារួម ការទទួលខុសត្រូវរបស់ក្រុមហ៊ុន គឺមានលំអិតនៅក្នុងកិច្ចសន្យា ក្នុងនោះមានលក្ខខណ្ឌទូទៅនៃកិច្ចសន្យា លក្ខខណ្ឌពិសេសនៃកិច្ចសន្យា លំអិតលក្ខណៈបច្ចេកទេស បញ្ជីបរិមាណតម្លៃ ប្លង់បច្ចេកទេស។
ក្រុមហ៊ុនមានភារកិច្ចទី១គឺអនុវត្តកិច្ចសន្យាដោយគោរពតាមលក្ខខណ្ឌកិច្ចសន្យាជាពិសេសជាមួយប្លង់បច្ចេកទេសលំអិតលក្ខណៈបច្ចេកទេស សេចក្តីណែនាំពីការត្រួតពិនិត្យគុណភាពសំណង់ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធរបស់ក្រសួងអប់រំយុវជននិងកីឡានិងនាយកដ្ឋានសំណង់ ។ ក្រុមហ៊ុនត្រូវធានាឲ្យបាននូវគុណភាពសំណង់និងសិរីរចនាការងារឲ្យបានតាមផែនការទាន់ពេលវេលា ។ក្រុមហ៊ុនត្រូវចាំបាច់ទទួលយកមកកែលំអនូវចំនុចខ្វះខាតរបស់ខ្លួន ដែលមានលក្ខណៈជាផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ ចេញដោយវិស្វករប្រចាំការដ្ឋាន វិស្វករក្រសួង ប្រធានបច្ចេកទេសអ្នកពិគ្រោះជាតិ និង អន្តរជាតិ ប្រធានគម្រោង ឬប្រធានគ្រប់គ្រងណាមួយ។

ក្រុមហ៊ុនត្រូវដឹងពីការជាក់ពិន័យក្នុងករណីការងារសាងសង់មិនគោរពតាមលំអិតលក្ខណៈបច្ចេកទេសនិងការងារយឺតយ៉ាវនៃសំណង់។

អ្នកម៉ៅការត្រូវអនុវត្តន៍គ្រប់តម្រូវការទាំងអស់ទាក់ទងនឹងការដាក់ពាក្យបើកប្រាក់ និងការដាក់ជូនពិនិត្យឯកសារ និងរូបថតនានា ។

អ្នកម៉ៅការត្រូវចូលរួមប្រជុំ ក្នុងករណីអញ្ជើញដោយនាយកដ្ឋានសំណង់ ឬក្រសួងអប់រំ យុវជន និង កីឡា ដើម្បីធ្វើការពិភាក្សាអំពីបច្ចេកទេសជាក់លាក់ និងបញ្ហានានាទាក់ទងនឹងការអនុវត្តន៍កិច្ចសន្យា ។

អ្នកម៉ៅការ ត្រូវដឹងថា ការលើសកាលបរិច្ឆេទនៃការសាងសង់ មិនគោរពតាមការណែនាំដដែលៗ អាចឈានទៅរកការលុបកិច្ចសន្យា មិនឲ្យចូលរួមក្នុងការដេញថ្លៃនាពេលអនាគតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

# ឧបសម្ព័ន្ធ